

# គោលការណ៍នៃការអនុវត្តល្អសម្រាប់អាជីវករ

*អង្គការអន្តរជាតិខាងការងារ - ការប្រកួតប្រជែង*

*វិស័យអាជីវកម្មខ្នាតតូចនៅអាស៊ាន*

TOU RISM

Small Business Competitiveness

ជាកម្មសិទ្ធិរបស់ ៖

International Labour Organization

asean

ការប្រកួតប្រជែងវិស័យអាជីវកម្មខ្នាតតូចនៅអាស៊ាន ដែលរៀបចំឡើងដោយអង្គការអន្តរជាតិខាងការងារ (ILO-SBC) ទទួលបានអាជ្ញាប័ណ្ណពី Creative Commons Attribution-NonCreative Commons Attribution-NonCommercial-ShareAlike 3.0 Unported License.

**អត្តសញ្ញាណ ៖** អ្នកត្រូវផ្តល់អំណះអំណាងយោងត្រឹមត្រូវ បង្ហាញពីអាជ្ញាប័ណ្ណ និងបញ្ជាក់ថាតើមានការកែប្រែ ឬយ៉ាងណា។ អ្នកត្រូវបំពេញតាមលក្ខខណ្ឌនេះឲ្យបានសមស្រប ប៉ុន្តែមិនមែនតាមវិធីដែលបង្ហាញថា អ្នកផ្តល់អាជ្ញាប័ណ្ណព្រមព្រៀងជាមួយអ្នក ឬការប្រើប្រាស់របស់អ្នកឡើយ។

**មិនមែនសម្រាប់ពាណិជ្ជកម្ម ៖** អ្នកមិនត្រូវប្រើប្រាស់ឯកសារនេះសម្រាប់គោលបំណងពាណិជ្ជកម្មឡើយ។

**ចែករំលែកតែមួយ ៖** ប្រសិនបើអ្នកកែសម្រួល ផ្លាស់ប្តូរ ឬបន្ថែមលើឯកសារនេះ អ្នកត្រូវបង្ហាញពីការចូលរួមចំណែករបស់ខ្លួន ក្រោមអាជ្ញាប័ណ្ណតែមួយនឹងអាជ្ញាប័ណ្ណដើម។

*https://creativecommons.org/licenses/by-nc-sa/3.0/legalcode*

TOURISM

Small Business Competitiveness

រៀបរៀងឡើងដោយ ៖

JAIF CBED ILO asean

## មាតិកា


សេចក្តីផ្តើម ........ 1

ការអភិវឌ្ឍសហគ្រាសតាមសហគមន៍ (C-BED) ........ 1

អាជីវករ ........ 2

កម្រងវគ្គបណ្តុះបណ្តាលសម្រាប់អាជីវករ ........ 2

របៀបប្រើប្រាស់គោលការណ៍នៃការអនុវត្តល្អ ........ 4

១. ការបង្កើតផែនការអាជីវកម្ម ........ 5

២. ការបង្កើតផែនការទីផ្សារ ........ 16

២.១. ផែនការទីផ្សារ ........ 16

២.២. ការវិភាគទីផ្សារ ៖ យោបល់ត្រឡប់របស់អតិថិជន ........ 20

២.៣. ការវិភាគទីផ្សារ ៖ ចំណែកទីផ្សារ និងគូប្រកួតប្រជែង ........ 24

២.៤. គោលការណ៍ "4 P" នៃការធ្វើទីផ្សារ ........ 27

៣. ការរៀបចំថវិកា និងការកំណត់ថ្លៃ ........ 37

៣.១. ការប៉ាន់ស្មានថ្លៃផលិតផល និងការលក់ប្រចាំខែ ........ 39

៣.២. ដឹងពីចំណាយរបស់អ្នក ........ 43

៣.៣. ប្រព័ន្ធតាមដាន និងកត់ត្រា ........ 55

# សេចក្តីផ្តើម

## សេចក្តីផ្តើម

### ការអភិវឌ្ឍសហគ្រាសតាមសហគមន៍ (C-BED)

ការអភិវឌ្ឍសហគ្រាសតាមសហគមន៍ (C-BED) គឺជាកម្មវិធីបណ្តុះបណ្តាល ដែលចំណាយតិច និងបង្កើតថ្មីដែលរៀបចំឡើងដោយអង្គការអន្តរជាតិខាងការងារ (ILO) ដើម្បីគាំទ្រការអភិវឌ្ឍជំនាញ និងការបង្កើនសិទ្ធិអំណាចដល់សហគមន៍មូលដ្ឋានក្នុងការកែលម្អជីវភាពរស់នៅ ផលិតភាព និងលក្ខខណ្ឌការងារកាន់តែប្រសើរឡើង។

ក្នុងនាមជាវិធីសាស្រ្តមួយនៃវគ្គបណ្តុះបណ្តាល កម្មវិធី C-BED មានលក្ខណៈពិសេស ពោលគឺកម្មវិធីនេះត្រូវបានបង្កើតឡើងតាមរបៀបមិត្តអប់រំមិត្ត ការសិក្សាផ្អែកតាមសកម្មភាព ដោយមិនមានតួនាទីគ្រូបង្រៀន អ្នកជំនាញ ឬទីប្រឹក្សាខាងក្រៅដែលមានជំនាញតាមផ្នែកឡើយ។ ផ្ទុយទៅវិញ សិក្ខាកាមក្នុងកម្មវិធី C-BED សហការគ្នាធ្វើសកម្មភាព និងកិច្ចពិភាក្សាជាបន្តបន្ទាប់ ដោយមានការណែនាំតាមជំហានសាមញ្ញៗក្នុងសៀវភៅណែនាំវគ្គបណ្តុះបណ្តាល។ ចំណេះដឹង ជំនាញ និងសមត្ថភាពថ្មីៗត្រូវបានបង្កើតឡើងតាមរយៈការបង្ហាត់បង្ហាញរបស់សិក្ខាកាម និងការចែករំលែកចំណេះដឹង និងបទពិសោធន៍ផ្ទាល់ខ្លួន។ តាមវិធីនេះ កម្មវិធីនេះគឺជាជម្រើសដែលចំណាយតិច និងមាននិរន្តរភាពសម្រាប់អង្គភាព ឬសហគមន៍នានា។

កម្មវិធី C-BED ត្រូវបានបង្កើតឡើងដោយផ្អែកលើកម្រងវគ្គបណ្តុះបណ្តាលស្នូល

ចំនួន ២ ដែលរៀបចំឡើងដើម្បីអភិវឌ្ឍសមត្ថភាពសម្រាប់ការចាប់ផ្ដើមអាជីវកម្ម និងការដំណើរការអាជីវកម្ម តាមរយៈការផ្ដោតសំខាន់លើការធ្វើទីផ្សារ ការគ្រប់គ្រងហិរញ្ញវត្ថុ និងការរៀបចំផែនការសកម្មភាព។ ទាំងនេះសុទ្ធតែជាចំណុចសំខាន់ក្នុងកម្មវិធី C-BED សម្រាប់អ្នកដែលចង់ក្លាយជាសហគ្រិន និងកម្មវិធី C-BED សម្រាប់អ្នកធ្វើអាជីវកម្មខ្នាតតូច។ ម្យ៉ាងវិញទៀត កម្មវិធីនេះកំពុងបង្កើតកម្រងឧបករណ៍ជាច្រើនសម្រាប់ពង្រឹងសមត្ថភាព និងបង្កើនជំនាញអាជីវកម្មសម្រាប់វិស័យមួយចំនួន។ កម្រងឧបករណ៍ទាំងនេះអាចយកមកអនុវត្តក្នុងវគ្គបណ្ដុះបណ្ដាលដាច់ដោយឡែក ឬចម្រុះក្នុងទម្រង់ជាម៉ូឌុល រួចបញ្ចូលទៅក្នុងកម្មវិធីដែលមានស្រាប់។

## អាជីវករ

អាជីវករលក់ផលិតផល និងផលិតផលិតផលសម្រាប់អតិថិជន និងអ្នកប្រើប្រាស់។ ពួកគេដើរតួនាទីសំខាន់ក្នុងតំបន់ទេសចរណ៍ ដោយសារតែអ្នកទេសចរណ៍ទិញវត្ថុកម្រ និងវត្ថុសិប្បកម្មពីអាជីវករទាំងនេះ។ ចំណុចនេះបានជួយបង្កើនបទពិសោធន៍របស់អ្នកទេសចរណ៍ និងបង្កើតជាឱកាសអាជីវកម្មដ៏សំខាន់សម្រាប់សហគមន៍មូលដ្ឋាន។ ការទិញ និងលក់ទំនិញទាមទារការគ្រប់គ្រងហិរញ្ញវត្ថុដោយប្រុងប្រយ័ត្ន ការទិញទំនិញ និងការធ្វើទីផ្សារសមស្របដើម្បីបង្កើតអាជីវកម្មជោគជ័យ និងរក្សានិរន្តរភាពជីវភាពរស់នៅ។

## កម្រងវគ្គបណ្តុះបណ្តាលសម្រាប់អាជីវករ

### កម្រងវគ្គបណ្តុះបណ្តាល

កម្រងវគ្គបណ្តុះបណ្តាលសម្រាប់អាជីវករគួរត្រូវបានប្រើប្រាស់ ដើម្បីជួយដល់អាជីវករថ្មីក្នុងការចាប់ផ្តើម និងកែលម្អអាជីវកម្មរបស់ខ្លួន។ វគ្គបណ្តុះបណ្តាលទាំងនេះផ្តោតលើគោលការណ៍អាជីវកម្មសំខាន់ៗសម្រាប់ជាមូលដ្ឋាន ដោយផ្អែកលើអ្វីដែលសិក្ខាកាមបានដឹងពីមុនអំពីការគ្រប់គ្រងអាជីវកម្មរបស់ខ្លួន និងជួយពួកគេឲ្យស្វែងយល់បន្ថែម។ម្យ៉ាងទៀត វាអាចប្រើប្រាស់ជាមូលដ្ឋាននៃការសិក្សាពីឧបករណ៍កម្មវិធី C-BED ផ្សេងទៀត ដូចជា SBO ឬ AE។ សិក្ខាកាមចែករំលែកបទពិសោធន៍ និងផ្តល់ផែនការសកម្មភាពអាទិភាព (យ៉ាងហោចណាស់ សកម្មភាព ៣ សម្រាប់បង្ហាញពីការកែលម្អអាជីវកម្មរបស់ពួកគេ)។ នៅពេលបញ្ចប់វគ្គបណ្តុះបណ្តាល សិក្ខាកាមនឹង ៖

- ពង្រឹង និងបង្កើនចំណេះដឹងមានស្រាប់ស្តីពីការអភិវឌ្ឍរបស់អាជីវករ
- មានសមត្ថភាពក្នុងការវិភាគផ្នែកការងារ ឬស្ថានភាពការងារបច្ចុប្បន្ន
- មានសក្តានុពលនៃការអភិវឌ្ឍសហគ្រាស
- កំណត់បាននូវជំហាន និងសកម្មភាពនានាដើម្បីកែលម្អអាជីវកម្មរបស់ខ្លួន ឬចាប់ផ្តើមគំនិតអាជីវកម្មថ្មី
- ធ្វើសេចក្តីសម្រេចពីសកម្មភាពនៅពេលអនាគត
- ចាប់ផ្តើមរៀបចំផែនការកិច្ចសហការ និងទំនាក់ទំនងប្រកបដោយ

ប្រសិទ្ធភាព។

## គោលការណ៍នៃការអនុវត្តល្អ (GPG) ៖

គោលការណ៍នេះត្រូវបានរៀបចំឡើង ដើម្បីជួយដល់អាជីវករទាំងអស់ក្នុងការចាប់ផ្តើម និងកែលម្អអាជីវកម្មរបស់ខ្លួន។ សិក្ខាកាមក្នុងវគ្គបណ្តុះបណ្តាលនេះនឹងទទួលបានព័ត៌មាន និងចំណេះដឹងស្តីពីគោលការណ៍នេះ។ យ៉ាងនេះក្តី សិក្ខាកាមដែលមិនបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល ក៏អាចប្រើប្រាស់គោលការណ៍នេះបានផងដែរ។ គោលការណ៍នេះមានឧបករណ៍អនុវត្ត គន្លឹះ និងលំហាត់ជាច្រើនសម្រាប់ជួយដល់អាជីវករថ្មីៗ។

## របៀបប្រើប្រាស់គោលការណ៍នៃការអនុវត្តល្អ

 ឧបករណ៍នៃការអនុវត្តល្អ

 លំហាត់

 ករណីសិក្សា

 និយមន័យ

 គន្លឹះ

 ព័ត៌មានបន្ថែមដែលត្រូវកត់សម្គាល់

# ការបង្កើតផែនការអាជីវកម្ម

## ១. ការបង្កើតផែនការអាជីវកម្ម

គោលបំណង ៖

- ជួយឲ្យអ្នកយល់ដឹងពីគោលបំណងនៃផែនការអាជីវកម្ម
- ផ្តោតលើចំណុចនានាក្នុងផែនការអាជីវកម្ម
- ជួយអ្នកក្នុងការវាយតម្លៃអាជីវកម្មរបស់ខ្លួន។

សៀវភៅណែនាំវគ្គបណ្តុះបណ្តាល ៖

- ផ្នែកនេះមានក្នុងវគ្គបណ្តុះបណ្តាលទី ២។

ផែនការអាជីវកម្មជាឯកសារដ៏សំខាន់សម្រាប់អាជីវកម្មខ្នាតតូចទាំងអស់ ព្រោះវាជួយឲ្យម្ចាស់អាជីវកម្ម ៖

- សរសេររៀបរាប់លម្អិតពីអាជីវកម្ម និងចងក្រងព័ត៌មានទាំងអស់
- ពិនិត្យផ្នែកទាំងអស់នៃអាជីវកម្មដើម្បីធានាដំណើរការ
- បង្ហាញអ្នកដទៃពីភាពជោគជ័យនៃអាជីវកម្ម
- ផ្តល់ភស្តុតាងសម្រាប់ប្រាក់កម្ចី ឬជំនួយមូលនិធិ។

**និយមន័យ ៖ ប្រព័ន្ធគ្រប់គ្រង**

ប្រព័ន្ធគ្រប់គ្រងជាកម្រងដំណើរការ និងនីតិវិធីជាជំហានសម្រាប់អាជីវកម្ម និងត្រូវបានប្រើប្រាស់សម្រាប់ជួយអ្នកក្នុងដំណើរការសកម្មភាពប្រចាំថ្ងៃដោយរលូន និងបំពេញបានតាមគោលដៅអាជីវកម្ម។ អត្ថប្រយោជន៍នៃប្រព័ន្ធនេះរួមមាន ៖

- ការប្រើប្រាស់ធនធានហិរញ្ញវត្ថុបានល្អបំផុត
- ការគ្រប់គ្រងពេលវេលា
- ការពេញចិត្តពីអតិថិជន

- ទំនាក់ទំនងល្អជាមួយអ្នកផលិត និងអ្នកផ្គត់ផ្គង់។

## ផែនការអាជីវកម្ម

ការរៀបចំផែនការអាជីវកម្ម នឹងផ្តល់នូវផែនទីចង្អុលបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍអាជីវកម្ម។ នៅពេលអ្នកបានអាន GPG អ្នកត្រូវបំពេញតារាងផ្ទៀងផ្ទាត់ខាងក្រោម ហើយអ្នកនឹងអាច ៖

- វាយតម្លៃអាជីវកម្មរបស់ខ្លួន (ចំណុចល្អ ចំណុចត្រូវកែលម្អ)
- ដឹងពីពាក្យគន្លឹះដែលត្រូវប្រើប្រាស់
- កំណត់ផ្នែកដែលត្រូវចាត់ចែង
- បែងចែកអ្នកទទួលខុសត្រូវ
- គូសបញ្ជាក់ពីការបែងចែកពេលវេលាដើម្បីធ្វើសកម្មភាពនានា។

តារាង ១.១ ៖ តារាងផ្ទៀងផ្ទាត់ផែនការអាជីវកម្ម

| | លាយលក្ខណ៍អក្សរ? | ត្រូវកែលម្អ? (បាទ/ចាស/ទេ) | អ្នកទទួលខុសត្រូវ | ពេលវេលា |
|---|---|---|---|---|
| វាយតម្លៃអាជីវកម្មរបស់អ្នក | | | | |
| រៀបរាប់ពីអាជីវកម្មរបស់អ្នក | | | | |
| ការវិភាគទីផ្សារ | | | | |
| ផែនការទីផ្សារ | | | | |
| ផែនការគ្រប់គ្រង | | | | |
| ផែនការហិរញ្ញវត្ថុ | | | | |

| | | | | |
|---|---|---|---|---|
| សម្គាល់ ៖ | | | | |

## តារាងផ្ទៀងផ្ទាត់

| តារាង ១.២ ៖ តារាងផ្ទៀងផ្ទាត់ផែនការអាជីវកម្ម | ✓ |
|---|---|
| ១. សេចក្តីសង្ខេបប្រតិបត្តិ (១-៥ ខាងក្រោម)<br>• ឈ្មោះអាជីវកម្ម<br>• ឈ្មោះម្ចាស់<br>• ទស្សនៈវិស័យ (ក្នុងរយៈពេល ៥ ឆ្នាំខាងមុខ)<br>• រចនាសម្ព័ន្ធអាជីវកម្ម អ្នកចូលរួម និងទីកន្លែង<br>• រៀបរាប់ពីផលិតផល និងរបៀបផលិត/ធ្វើ<br>• ឱកាសទីផ្សារសម្រាប់ការលក់<br>• គោលដៅការលក់ក្នុងរយៈពេល ១, ២, ៣ ឆ្នាំខាងមុខ<br>• នៅពេលខ្ចីប្រាក់ ៖ រាប់បញ្ចូលចំនួន របៀបប្រើប្រាស់ និងរបៀបដែលអ្នកធានាការទូទាត់សង ដោយផ្អែកលើជោគជ័យអាជីវកម្មរបស់អ្នក។ | |
| ២. ការរៀបរាប់ពីអាជីវកម្ម<br>• លក្ខណៈរបស់ផលិតផល ជាពិសេសធៀបនឹងគូប្រកួតប្រជែង<br>• ខ្លឹមសារសង្ខេបនៃអាជីវកម្ម ដូចជា ការកំណត់ថ្លៃ និងការធ្វើទីផ្សារ | |
| ៣. ការវិភាគទីផ្សារ<br>• ការរៀបរាប់ជាក់លាក់ពីផលិតផល ដូចជា ទំហំ វត្ថុធាតុ ទម្ងន់<br>• ការរៀបរាប់ពីអតិថិជន និងមូលហេតុដែលពួកគេទិញផលិតផលរបស់អ្នក<br>• ការវាយតម្លៃសក្តានុពលទីផ្សារ (ឧ. ភ្ញៀវទេសចរណ៍ច្រើន ឬសណ្ឋាគារថ្មីៗច្រើន)<br>• ទីផ្សារលក់ប្រកួតប្រជែង មូលហេតុដែលអ្នកនឹងមានប្រៀបជាអ្នកដទៃ<br>• ចំណុចលក់លេចធ្លោរ (ឧ. ប្រភពក្នុងមូលដ្ឋាន សរីរាង្គ ឬមាននិរន្តរភាព) | |

| | |
|---|---|
| ៤. ផែនការគ្រប់គ្រង<br>• រចនាសម្ព័ន្ធអាជីវកម្ម អ្នកទទួលខុសត្រូវ និងអ្នកគាំទ្រអាជីវកម្ម | |
| ៥. ផែនការទីផ្សារ<br>• ថ្លៃសមស្របសម្រាប់អតិថិជន និងថ្លៃរបស់គូប្រកួតប្រជែង<br>• ការចែកចាយ (ឧ. កន្លែងលក់ ការកម្មង់តាមប្រៃសណីយ៍។ល។)<br>• ការផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយ។ | |
| ៦. ផែនការហិរញ្ញវត្ថុ<br>• ទឹកប្រាក់កម្ចីចាំបាច់សម្រាប់ការអភិវឌ្ឍ (ឬចាប់ផ្ដើម) អាជីវកម្ម<br>• ហិរញ្ញប្បទានថ្ងៃខាងមុខ នៅពេលអស់ប្រាក់កម្ចី ដោយផ្អែកលើកំណើនប្រាក់ចំណេញ<br>• ការព្យាករប្រសិទ្ធភាពការងារ ដូចជា តួលេខប៉ាន់ស្មានដើម្បីបង្ហាញពីកំណើន<br>• របាយការណ៍ហិរញ្ញវត្ថុ ការប៉ាន់ស្មានប្រាក់ចំណូលសរុប ចំណាយសរុប និងការវិនិយោគសរុបរបស់អ្នក (រួមទាំងទ្រព្យសកម្ម)<br>• របាយការណ៍ប្រាក់ចំណូលដែលបង្ហាញពីប្រសិទ្ធភាពការងារប៉ាន់ស្មាន ក្នុងរយៈពេលចាប់ពី ៣ ឆ្នាំឡើងទៅ ប្រាក់ចំណូលសរុប និងចំណាយសរុប<br>• ការវិភាគចំណុចស្រង់ដើមដែលបង្ហាញថា ប្រាក់ចំណូលពីការលក់គឺខ្ពស់ជាងចំណាយ (ឧ. ចំណាយក្នុងអាជីវកម្ម និងទុនចំណាយ)<br>• ការព្យាករលំហូរសាច់ប្រាក់ដើម្បីបង្ហាញពីធនធានហិរញ្ញវត្ថុចាំបាច់<br>• មូលធន (ទ្រព្យសកម្ម) ដូចជា សំភារៈក្នុងអាជីវកម្ម វត្ថុធាតុ និងគ្រឿងបរិក្ខាររបស់អ្នក។ | |

១. ខាងក្រោមនេះជាតារាងបង្ហាញពីលក្ខណវិនិច្ឆ័យនៃអាជីវកម្មជោគជ័យ។ អាន រួចពន្យល់ពីអត្ថន័យតាមការយល់ឃើញរបស់អ្នក។ ប្រសិនបើអ្នកមិនដឹងពីអត្ថន័យរបស់ឃ្លា សូមសាកសួរនរណាម្នាក់ ឬស្រាវជ្រាវក្នុងវចនានុក្រម ឬគេហទំព័រ។

២. ជ្រើសរើសលក្ខណវិនិច្ឆ័យចំនួន ៥ ដែលអ្នកយល់ថាមានសារៈសំខាន់បំផុត រួចសរសេរក្នុងតារាងខាងក្រោម និងពន្យល់ពីមូលហេតុរបស់អ្នក។

៣. ដាក់ពិន្ទុអាជីវកម្មរបស់អ្នក ៖ ល្អ ធម្មតា ឬត្រូវកែលម្អ ដោយប្រើប្រាស់លក្ខណវិនិច្ឆ័យទាំងនេះ។

៤. ដាក់ពិន្ទុខ្លួនអ្នកដោយផ្អែកលើលក្ខណវិនិច្ឆ័យទាំង ៣២។ ព្យាយាមបញ្ចូលសកម្មភាពដែលអ្នកអាចធ្វើបានដើម្បីកែលម្អអាជីវកម្មរបស់អ្នក។

| តារាង ១.៣ ៖ កត្តាកំណត់ជោគជ័យក្នុងអាជីវកម្ម | | |
|---|---|---|
| ពាក្យគន្លឹះ | | |
| កន្លែងប្រកបអាជីវកម្ម/លក់ | ដឹងពីតម្រូវការរបស់អតិថិជន | តម្លៃលក់ល្អប្រសើរ |
| ដឹងពីចំណាយក្នុងអាជីវកម្មរបស់ខ្ញុំ | ថ្លៃដើមផលិតផល | ការឧបត្ថម្ភពីគ្រួសារ |
| ផលិតផលមានគុណភាពល្អ | បុគ្គលិក/និយោជិតដែលរវល់ | បច្ចេកទេសធ្វើទីផ្សារល្អប្រសើរ |
| ការទាក់ទាញអតិថិជន | ផលិតផលដែលមាន | និយោជិតជំនាញ |
| ការស្តុកទុកបានល្អ | មិនមានផលិតផលខូចគុណភាព | ភាពអាចរកបាននៃប្រាក់កម្ចី |
| ដឹងពីកិច្ចការប្រចាំថ្ងៃរបស់អ្នក | លក្ខខណ្ឌការងារល្អប្រសើរ | ការរៀបចំល្អប្រសើរ |
| កន្លែងធ្វើការស្អាត | អតិថិជនគ្រប់គ្រាន់ | ការតាមដានសាច់ប្រាក់ |
| កន្លែងធ្វើការមានការរៀបចំ | ដឹងពីប្រភេទចំណាយរបស់អ្នក | អ្នកជំនួញដ៏ល្អ |
| ពេញចិត្តនឹងអាជីវកម្មរបស់អ្នក | ផលិតផលមានសភាពល្អ | ការដឹងពីចំណូលរបស់អ្នក |
| គ្រឿងបរិក្ខារមានដំណើរការល្អ | ដឹងពីកិច្ចការរបស់និយោជិត | ការដឹងពីបំណុលរបស់អ្នក |
| អតិថិជនត្រឡប់មករកអ្នកវិញ | | |
| លក្ខណវិនិច្ឆ័យនៃភាពជោគជ័យក្នុងអាជីវកម្មរបស់ខ្ញុំ | | |
| <u>លក្ខណវិនិច្ឆ័យសំខាន់ៗទាំង ៥</u> | មូលហេតុនៃការជ្រើសរើស | តើអ្នកធ្វើកិច្ចការនេះបានល្អប្រសើរ ឬទេ? ដាក់ពិន្ទុ ៖<br>☺ ល្អ |

| | | |
|---|---|---|
| | | ☹ ធម្មតា<br>☹ ត្រូវកែលម្អ |
| 1. | | |
| 2. | | |
| 3. | | |
| 4. | | |
| 5. | | |

តារាង ១.៤ ៖ លក្ខណវិនិច្ឆ័យនៃអាជីវកម្មជោគជ័យ

| | កត្តាកំណត់ជោគជ័យ | ☺<br>ល្អ | ☹<br>ធម្មតា | ☹<br>មិនល្អ | តើខ្ញុំអាចធ្វើអ្វីបានខ្លះ? |
|---|---|---|---|---|---|
| 1. | កន្លែងប្រកបអាជីវកម្ម/លក់ | | | | |
| 2. | ដឹងពីចំណាយក្នុងអាជីវកម្មរបស់ខ្ញុំ | | | | |
| 3. | គុណភាពផលិតផល | | | | |
| 4. | អតិថិជន | | | | |
| 5. | ការស្តុកទុកផលិតផល | | | | |
| 6. | កិច្ចការប្រចាំថ្ងៃ និងទម្លាប់ | | | | |
| 7. | កន្លែងធ្វើការស្អាត | | | | |
| 8. | កន្លែងធ្វើការមានការរៀបចំ | | | | |
| 9. | ពេញចិត្តនឹងអាជីវកម្ម | | | | |
| 10. | ដំណើរការគ្រឿងបរិក្ខារ | | | | |
| 11. | ដឹងពីបំណុលរបស់អ្នក | | | | |
| 12. | ដឹងពីតម្រូវការអតិថិជន | | | | |
| 13. | ថ្លៃដើមផលិតផល | | | | |

| | | | | | |
|---|---|---|---|---|---|
| 14. | តម្លៃលក់ | | | | |
| 15. | ផលិតផលដែលមាន | | | | |
| 16. | ផលិតផលខូចគុណភាព | | | | |
| 17. | ផលិតភាពរបស់បុគ្គលិក | | | | |
| 18. | លក្ខខណ្ឌការងារបុគ្គលិក | | | | |
| 19. | អតិថិជនគ្រប់គ្រាន់ | | | | |
| 20. | ចំណាយសរុប | | | | |
| 21. | ផលិតផលមានសភាពល្អ | | | | |
| 22. | ដឹងពីកិច្ចការរបស់បុគ្គលិក | | | | |
| 23. | អតិថិនជនត្រឡប់មកវិញ | | | | |
| 24. | តម្លៃលក់ | | | | |
| 25. | គ្រួសារជួយឧបត្ថម្ភអ្នក | | | | |
| 26. | បច្ចេកទេសធ្វើទីផ្សារ | | | | |
| 27. | បុគ្គលិកជំនាញ និងគួរឲ្យទុកចិត្ត | | | | |
| 28. | ភាពអាចរកបាននៃប្រាក់កម្ចី | | | | |
| 29. | ការកត់ត្រាចូលបញ្ជី | | | | |
| 30. | ការតាមដានលំហូរសាច់ប្រាក់ | | | | |
| 31. | អ្នកជំនួញល្អ | | | | |
| 32 | ដឹងពីប្រាក់ចំណូលរបស់អ្នក | | | | |

តើអ្នកអាចរៀបពាក្យទាំងនេះជាក្រុមបានដែរ ឬទេ? ឧ. ពាក្យដែលពាក់ព័ន្ធនឹងហិរញ្ញវត្ថុ ការធ្វើទីផ្សារ បុគ្គលិក។ល។

តើអ្នកអាចគិតពីការរៀបលំដាប់ពាក្យទាំងនេះទៅតាមកម្រិតភាពងាយស្រួល-លំបាក ក្នុងការលើកឡើងបានដែរ ឬទេ?

តើអ្នកអាចគិតពីរបៀបដែលអ្នកនឹងធ្វើការផ្លាស់ប្តូរ ឬទេ? តើអ្នកដឹងពីអ្វីដែលត្រូវធ្វើ ឬទេ? (ឧ. មានការរៀបចំប្រសើរជាងមុន ស្វែងរកការណែនាំពីអ្នកដទៃ ឬស្រាវជ្រាវរកឯកសាររៀនសូត្រ ដូចជា សៀវភៅ

ទស្សនាវដ្តី អ៊ីនធើរណិត)។

SWOT

- ចំណុចខ្លាំង (S) ៖ ក្នុងអាជីវកម្ម
- ចំណុចខ្សោយ (W) ៖ ក្នុងអាជីវកម្ម
- ឱកាស (O) ៖ មកពីខាងក្រៅអាជីវកម្ម
- ការគំរាមកំហែង (T) ៖ មកពីខាងក្រៅអាជីវកម្ម

**ចំណុចខ្លាំង** ៖ ធ្វើឲ្យអាជីវកម្មអ្នកទទួលបានគុណប្រយោជន៍លើអាជីវកម្មស្រដៀងគ្នា។ ឧ. ផលិតផលមានគុណភាព ឬទីតាំងល្អសម្រាប់ការលក់។

**ចំណុចខ្សោយ** ៖ ផ្នែកដែលអ្នក និងអាជីវកម្មរបស់អ្នកមិនមានលក្ខណៈល្អប្រសើរ។ ឧ. អ្នកផ្គត់ផ្គង់មិនចិតថេរ ឬថ្លៃដើមខ្ពស់លើការដឹកជញ្ជូនផលិតផល។

**ឱកាស** ៖ ជាអ្វីដែលកើតមានក្រៅអាជីវកម្មរបស់អ្នក ដែលអាចជួយដល់អ្នកបាន។ ឧ. ផ្ទះសំណាក់ថ្មីក្នុងតំបន់ ឬអ្នកទេសចរណ៍ដែលប្រើប្រាស់ចំណតឡានក្រុង។

**ការគំរាមកំហែង** ៖ ជាអ្វីដែលស្ថិតនៅខាងក្រៅអាជីវកម្ម ដែលអាចបង្កបញ្ហាដល់អាជីវកម្មរបស់អ្នក និងកាត់បន្ថយប្រាក់ចំណេញ។ ឧ. គំនិតអាជីវកម្មរបស់អ្នកមានការពេញនិយម ហើយមនុស្សចម្លងគំនិតនោះ ឬមានភ្ញៀវទេសចរណ៍តិចតួចដែលនឹងទិញផលិតផលរបស់អ្នក។

នៅពេលចំណុចខ្លាំង និងឱកាសមានច្រើនជាងចំណុចខ្សោយ និងការគំរាមកំហែង អ្នកមានភាពម្ចាស់ការលើអាជីវកម្ម និងអាចប្រឈមនឹងហានិភ័យរំពឹងទុកបាន។ នៅពេលចំណុចខ្សោយ និងការគំរាមកំហែងមានច្រើនជាងចំណុចខ្លាំង និងឱកាស អ្នកត្រូវចាត់វិធានការដោយប្រុងប្រយ័ត្នដើម្បីសង្គ្រោះអាជីវកម្ម។

ខាងក្រោមនេះជាឧទាហរណ៍មួយនៃការវិភាគ SWOT។

<table>
<tr><th colspan="2">តារាង ១.៥ ៖ ការវិភាគ SWOT</th></tr>
<tr><td>ចំណុចខ្លាំង</td><td>ចំណុចខ្សោយ</td></tr>
<tr><td>ទីតាំងដំបូងគេក្នុងទីផ្សារមូលដ្ឋាន<br>លក់ផលិតផលច្រើនប្រភេទ<br>ស្គាល់អ្នកផលិតវត្ថុសិប្បកម្មជាច្រើន<br>មានជំនាញផ្គត់ផ្គង់ផលិតផល និងចរចាតម្លៃផលិតផលបានល្អ</td><td>ការគ្រប់គ្រងហិរញ្ញវត្ថុមិននឹងនរ<br>មិនមានការធ្វើទីផ្សារ ឬផែនការអភិវឌ្ឍន៍</td></tr>
<tr><td>ឱកាស</td><td>ការគំរាមកំហែង</td></tr>
<tr><td>ភ្ញៀវទេសចរណ៍ជាច្រើនមកកាន់តំបន់នេះ<br>មានសណ្ឋាគារ និងផ្ទះសំណាក់កាន់តែច្រើន<br>មានទំនាក់ទំនងល្អជាមួយប្រជាជនមូលដ្ឋាន និងអាជីវកម្មជាច្រើន</td><td>គូប្រកួតប្រជែងអាចចាប់ផ្តើមអាជីវកម្ម<br>ស្រដៀងគ្នាបានដោយងាយ ដែលអាចធ្វើឲ្យការលក់ថយចុះ។</td></tr>
<tr><td colspan="2">មានចំណុចខ្លាំងច្រើនជាងចំណុចខ្សោយ? បាទ/ចាស ☒ ទេ ☐<br>មានឱកាសច្រើនជាងការគំរាមកំហែង? បាទ/ចាស ☒ ទេ ☐<br>តើខ្ញុំអាចកែលម្អចំណុចខ្សោយ និងការគំរាមកំហែងបានយ៉ាងដូចម្តេច?<br>ខ្ញុំនឹងកែលម្អអាជីវកម្មដោយផ្តោតសំខាន់លើហិរញ្ញវត្ថុ និងការធ្វើទីផ្សារ។<br>ខ្ញុំនឹងផ្តល់សេវាល្អដល់អ្នកផលិត និងអតិថិជនដើម្បីឲ្យខ្ញុំនៅតែអាចបន្តឈានមុខក្នុងអាជីវកម្មបាន។<br>ខ្ញុំនឹងប្រើប្រាស់មិត្តភក្តិ គ្រួសារ និងបណ្តាញរបស់ខ្ញុំដើម្បីគាំទ្រ និងជំរុញអាជីវកម្មរបស់ខ្ញុំ។</td></tr>
</table>

| តារាង ១.៦ ៖ ការវិភាគ SWOT | |
| --- | --- |
| ចំណុចខ្លាំង | **ចំណុចខ្សោយ** |
| | |
| ឱកាស | ការគំរាមកំហែង |
| | |

មានចំណុចខ្លាំងច្រើនជាងចំណុចខ្សោយ? បាទ/ចាស ☒ ទេ ☐

មានឱកាសច្រើនជាងការគំរាមកំហែង? បាទ/ចាស ☒ ទេ ☐

តើខ្ញុំអាចកែលម្អចំណុចខ្សោយ និងការគំរាមកំហែងយ៉ាងដូចម្ដេច?

ខ្ញុំនឹង

ខ្ញុំនឹង

ខ្ញុំនឹង

# ការបង្កើតផែនការទីផ្សារ

## ២. ការបង្កើតផែនការទីផ្សារ

គោលបំណង ៖

- ជួយអ្នកឲ្យយល់ពីគោលបំណងនៃផែនការទីផ្សារ
- ផ្តោតលើសមាសធាតុក្នុងផែនការទីផ្សារ

សៀវភៅណែនាំវគ្គបណ្តុះបណ្តាល ៖

- ផ្នែកនេះមានក្នុងវគ្គបណ្តុះបណ្តាលទី ៣។

### ២.១. ផែនការទីផ្សារ

ផែនការទីផ្សារនឹងជួយអ្នកប្រមូលព័ត៌មានពីអាជីវកម្ម និងរៀបចំសកម្មភាពទីផ្សារដែលមានប្រសិទ្ធភាព និងជួយបង្កើនការលក់របស់អ្នក។ កំណត់សម្គាល់មួយចំនួនសម្រាប់ការធ្វើផែនការទីផ្សាររួមមាន ៖

- សរសេររៀបរាប់លម្អិតពីអាជីវកម្ម និងចងក្រងព័ត៌មានទាំងអស់
- ពិនិត្យផ្នែកទាំងអស់នៃអាជីវកម្មដើម្បីធានាដំណើរការ
- បង្ហាញអ្នកដទៃពីភាពជោគជ័យនៃអាជីវកម្ម
- ផ្តល់ភស្តុតាងសម្រាប់ប្រាក់កម្ចី ឬជំនួយមូលនិធិ។

**និយមន័យ**

ការធ្វើទីផ្សារជាដំណើរការនៃការបង្ហាញពីតម្លៃរបស់ផលិតផល ឬសេវាមួយដល់អតិថិជនដើម្បីលក់ផលិតផល ឬសេវានោះ។ ការធ្វើទីផ្សារពាក់ព័ន្ធនឹង ៖

- ការវិភាគទីផ្សារ
- ការរៀបរាប់ពីផលិតផល
- ការលក់
- ការផ្សព្វផ្សាយ

- ការផ្សាយពាណិជ្ជកម្ម

**តារាងផ្ទៀងផ្ទាត់**

ការប្រើប្រាស់តារាងផ្ទៀងផ្ទាត់នេះ នឹងផ្តល់ឲ្យអ្នកនូវផែនទីចង្អុលបង្ហាញផ្លូវ សម្រាប់បង្កើតផែនការទីផ្សារ។ នៅពេលអ្នកបានអានផ្នែកស្តីពីការធ្វើទីផ្សារនេះ អ្នកនឹងអាចបំពេញតារាងផ្ទៀងផ្ទាត់ខាងក្រោម។ វានឹងជួយអ្នកឲ្យដឹងពី ៖

- ផលិតផលដែលជាតម្រូវការរបស់អតិថិជន
- ផលិតផលដែលត្រូវលក់
- អតិថិជនគោលដៅ
- របៀបលក់ផលិតផល

តារាង ២.១.១ ៖ តារាងផ្ទៀងផ្ទាត់ផែនការទីផ្សារ

| | លាយលក្ខណ៍អក្សរ? | ត្រូវកែលម្អ (បាទ/ចាស/ទេ) | អ្នកទទួលខុសត្រូវ | ពេលវេលា |
|---|---|---|---|---|
| រៀបរាប់ពីអាជីវកម្ម | | | | |
| យោបល់ត្រឡប់របស់អតិថិជន | | | | |
| គូប្រកួតប្រជែង | | | | |
| ការវិភាគទីផ្សារ | | | | |
| ផលិតផល | | | | |
| ទីកន្លែង | | | | |
| ការផ្សព្វផ្សាយ និងការផ្សាយពាណិជ្ជកម្ម | | | | |

សម្គាល់ ៖

**ករណីសិក្សា**

ផុមស៊ីទុរីរស់នៅក្នុងទីក្រុងតូចមួយ ជាមួយកូនៗវ័យជំទង់ពីរនាក់របស់គាត់។ គាត់ទិញ និងលក់វត្ថុសិប្បកម្មផលិតក្នុងស្រុក ក្នុងផ្សារថ្មើរជើងមួយនៅថ្ងៃសៅរ៍។ អាជីវកម្មនេះមានដំណើរការល្អក្នុងរយៈពេលពីរឆ្នាំកន្លងមក។ ផុមអាចទទួលបានវត្ថុសិប្បកម្មគ្រប់គ្រាន់ពីភូមិជុំវិញ ហើយគាត់មានការផ្លាស់ប្តូរស្តុកយ៉ាងល្អ។ គាត់កំពុងគិតចង់ពង្រីកអាជីវកម្មដោយរាប់បញ្ចូលជម្រើសផ្សេងទៀតសម្រាប់ការលក់ ដោយសារគាត់បានកត់សម្គាល់ថា មានភ្ញៀវទេសចរណ៍កាន់តែច្រើនក្នុងតំបន់ដែលស្នាក់នៅក្នុងផ្ទះសំណាក់ និងផ្ទះអ្នកស្រុក។ ផុមបានវាយតម្លៃអាជីវកម្មបច្ចុប្បន្នរបស់ខ្លួន និងចង់កែលម្អការធ្វើទីផ្សារ និងការគ្រប់គ្រងហិរញ្ញវត្ថុ។ ក្រៅពីនេះ គាត់ចង់ខ្ចីប្រាក់ពីពូរបស់គាត់ ដែលផ្តល់លក្ខខណ្ឌសងប្រាក់ដ៏ល្អ ដូចជា អត្រាការប្រាក់ទាបបំផុត។ មុនពេលគាត់វិនិយោគ គាត់ចង់ដឹងពីសុវត្ថិភាពសាច់ប្រាក់របស់គាត់ និងចង់ដឹងថាតើផុមអាចសងប្រាក់ឲ្យគាត់តាមខែបានដែរ ឬយ៉ាងណា។ ដូច្នេះ គាត់បានតម្រូវឲ្យផុមរៀបចំផែនការអាជីវកម្មដោយមានការព្យាករមួយចំនួន។

**និយមន័យ**

- **អ្នកផលិត ៖** ធ្វើ/ផលិតផលិតផល
- **អ្នកលក់ដុំ ៖** ផ្គត់ផ្គង់ផលិតផលក្នុងបរិមាណច្រើន (ដុំ) និងលក់ឲ្យអ្នកលក់រាយ។ ពួកគេមិនលក់ដោយផ្ទាល់ដល់សាធារណៈជនឡើយ។ ប្រសិនបើអ្នកលក់រាយអាចឈប់ទិញពីអ្នកលក់ដុំ (ឧ. ពួកគេទទួលបានផលិតផលពីអ្នកផលិត) ពួកគេមិនចាំបាច់បង់ចំណាយរបស់អ្នកលក់ដុំឡើយ។ ដូច្នេះ

ផលិតផលតែងតែមានតម្លៃថោក។ គេនឹងត្រូវការអ្នកលក់ដុំ ប្រសិនបើអ្នកលក់មិនអាចទទួលបានផលិតផលពីអ្នកផលិត (មិនស្គាល់បុគ្គល ឬទីកន្លែងត្រូវទិញ ឬមានតម្លៃថ្លៃក្នុងការធ្វើដំណើរទៅទិញផលិតផលពីអ្នកផលិត)។

- **អ្នកផ្តល់សេវា (ប្រតិបត្តិករ)** ៖ មិនលក់ផលិតផល ប៉ុន្តែលក់សេវា (ឧ. ការជួសជុលម៉ាស៊ីនដេរ ការកាត់សក់)។

| តារាង ២.១.២ ៖ ការរៀបរាប់ពីអាជីវកម្មរបស់ផុមស៊ីទុរី | |
|---|---|
| ឈ្មោះអាជីវកម្ម | |
| ប្រភេទអាជីវកម្ម | ❑ អ្នកផលិត ❑ អ្នកផ្តល់សេវា<br>☑ អ្នកលក់រាយ ❑ អ្នកលក់ដុំ |
| តើផលិតផលបំពេញតម្រូវការអ្វីខ្លះ? | វត្ថុសិប្បកម្មសម្រាប់ប្រជាជនមូលដ្ឋាន អ្នកដំណើរ និងភ្ញៀវទេសចរណ៍ដើម្បីគាំទ្រសិប្បករក្នុងមូលដ្ឋាន (ឧ. ការទទួលខុសត្រូវក្នុងសង្គម) អំណោយសម្រាប់ពិធីបុណ្យ និងព្រឹត្តិការណ៍ពិសេស (ឧ. ទិវាបុណ្យម្តាយ និងប័ណ្ណសម្រាប់ថ្ងៃទទួលសញ្ញាបត្រ) និងវត្ថុអនុស្សាវរីយ៍ពីថ្ងៃឈប់សម្រាក/ដំណើរកំសាន្តរបស់ពួកគេ។ |
| តើអាជីវកម្មនេះនឹងផលិតផលិតផលអ្វី? | គ្មានទេ។ ផលិតផលត្រូវបានទិញពីសិប្បករក្នុងមូលដ្ឋាន។ |
| អតិថិជនគោលដៅ? | អ្នកដែលរស់នៅ ធ្វើការ ឬធ្វើដំណើរកំសាន្តក្នុងទីក្រុង។ |
| របៀបលក់ផលិតផល? | ក្នុងទីផ្សារ ផ្ទះសំណាក់ ចំណតឡានក្រុង ហាងកាហ្វេ និងក្នុងទីផ្សារដែលមាន "ព្រឹត្តិការណ៍" ពិសេស (ឧ. ការទទួលសញ្ញាបត្រ ៖ ក្រៅសាលានៅថ្ងៃទទួលសញ្ញាបត្រ)។ |

### ការរៀបរាប់ពីអាជីវកម្ម

| តារាង ២.១.៣ ៖ ការរៀបរាប់ពីអាជីវកម្ម | |
|---|---|
| ឈ្មោះអាជីវកម្ម ៖ | |
| ប្រភេទអាជីវកម្ម ៖ | ❑ អ្នកផលិត ❑ អ្នកផ្តល់សេវា<br>❑ អ្នកលក់រាយ ❑ អ្នកលក់ដុំ<br>❑ ផ្សេងៗ |
| តើផលិតផលបំពេញតម្រូវការអ្វីខ្លះ? | |
| តើអាជីវកម្មនឹងផលិតផលិតផលអ្វី? | |
| អតិថិជនគោលដៅ? | |
| របៀបលក់ផលិតផល? | |

## ២.២. ការវិភាគទីផ្សារ ៖ យោបល់ត្រឡប់របស់អតិថិជន

ជំហានបន្ទាប់នៃការសរសេរផែនការទីផ្សារគឺការវិភាគទីផ្សារ ៖ អតិថិជន និងគូប្រកួតប្រជែងរបស់អ្នក។

១. ពិភាក្សាជាមួយអតិថិជនដែលមានសក្តានុពល ៖

- តើពួកគេចង់ទិញផលិតផលអ្វី?
- តើពួកគេយល់យ៉ាងណាចំពោះអ្នកផ្សេងទៀតដែលលក់ផលិតផលស្រដៀងគ្នា?

២. អង្កេតអាជីវកម្មរបស់គូប្រកួតប្រជែង ៖

- តើពួកគេលក់ផលិតផលដែលមានគុណភាព ប្រភេទ ទំហំ។ល។ អ្វីខ្លះ?
- តើពួកគេកំណត់ថ្លៃប៉ុន្មាន?

- តើពួកគេទាក់ទាញអតិថិជនដោយរបៀបណា? តើពួកគេមានការផ្តល់ជូន និងការបញ្ចុះតម្លៃអ្វីខ្លះ?

៣. សាកសួរមិត្តភក្តិ គ្រួសារ និងអ្នកជំនួញផ្សេងទៀត ៖

- តើផលិតផលអ្វីដែលលក់ដាច់?
- តើពួកគេយល់យ៉ាងណាចំពោះអាជីវកម្មរបស់អ្នក?
- តើពួកគេយល់យ៉ាងណាចំពោះផលិតផលគូប្រកួតប្រជែងរបស់អ្នក?
- តើពួកគេទាក់ទាញអតិថិជនដោយរបៀបណា?

៤. អ្នកត្រូវបន្តកែលម្អដើម្បីធានាថា អាជីវកម្មរបស់អ្នកនៅតែមានជោគជ័យ។ រូបភាពខាងក្រោមបង្ហាញពីវដ្តនៃការអនុវត្ត។




**សេវាអតិថិជន**

ទម្រង់នេះអាចប្រើប្រាស់ដើម្បីអង្កេតលើអតិថិជនជាច្រើន។ សូមថតចម្លងទម្រង់នេះឲ្យបានច្រើនច្បាប់លើក្រដាស A4 ដើម្បីសន្សំសំចៃថ្លៃថតចម្លង។

| តារាង ២.២.១ ៖ ការអង្កេតអតិថិជន | | | |
|---|---|---|---|
| ការអង្កេតអតិថិជន | ☹ | 😐 | ☺ |
| គុណភាពផលិតផលរបស់ខ្ញុំ | | | |
| ថ្លៃផលិតផលរបស់ខ្ញុំ | | | |
| ដែន និងប្រភេទផលិតផលរបស់ខ្ញុំ | | | |
| ទំហំផលិតផលរបស់ខ្ញុំ | | | |
| ផលិតផលស្រដៀងគ្នារបស់ពាណិជ្ជករក្នុងទីផ្សារ (គុណភាព ថ្លៃ ប្រភេទ ទំហំ) | | | |
| សូមបញ្ចេញមតិយោបល់របស់អ្នកពាក់ព័ន្ធនឹងសំណួរខាងលើ ៖ | | | |
| តើអ្នកមានមតិអ្វីដើម្បីជួយខ្ញុំកែលម្អអាជីវកម្មដែរ ឬទេ? | | | |
| សូមបញ្ចេញមតិយោបល់របស់អ្នកពាក់ព័ន្ធនឹងសំណួរខាងលើ ៖ | | | |
| សូមអរគុណ! ប្រសិនបើអ្នកចង់ផ្តល់អាសយដ្ឋានទំនាក់ទំនងរបស់អ្នក (អ៊ីម៉ែល/លេខទូរស័ព្ទ) សូមសរសេរក្នុងចន្លោះនេះ ៖ | | | |

អ្នកអាចប្រើប្រាស់ទម្រង់ខាងក្រោម ដើម្បីប្រមូលយោបល់ត្រឡប់អំពីអាជីវកម្មរបស់អ្នក ឬក៏អ្នកអាចប្រើវានៅពេលពិភាក្សាជាមួយអតិថិជន។

| តារាង ២.២.១ ៖ យោបល់ត្រឡប់របស់អតិថិជន | |
|---|---|
| ១. មតិយោបល់ និងយោបល់ត្រឡប់របស់អតិថិជន | |
| តើអ្នកចូលចិត្តផលិតផល (របស់ខ្ញុំ) អ្វីខ្លះ? ហេតុអ្វី? | |
| តើមានផលិតផលដែលអ្នកចង់ | |

| | |
|---|---|
| ឲ្យខ្ញុំស្តុកទុកដែរ ឬទេ? | |
| តើអ្នកយល់យ៉ាងណាចំពោះអាជីវកម្មរបស់ខ្ញុំ? សូមផ្តល់ព័ត៌មានពិត។ | |
| តើថ្លៃផលិតផលរបស់ខ្ញុំសមស្រប ឬទេ? ៖ មិនថ្លៃពេក មិនថោកពេក? | |
| ២. ការអង្កេតរបស់ខ្ញុំពីអាជីវកម្មសិប្បកម្មផ្សេងទៀត | |
| ការវាយតម្លៃពីគុណភាពផលិតផលគូប្រកួតប្រជែង (ឧ. អ្នកលក់វត្ថុសិប្បកម្មផ្សេងទៀត) | |
| តើគុណភាពផលិតផលទាំងនោះមានលក្ខណៈដូចម្តេចដែរ ធៀបនឹងថ្លៃដើមផលិតផលគូប្រកួតប្រជែង? | |
| តើគូប្រកួតប្រជែងប្រើប្រាស់បច្ចេកទេសទីផ្សារអ្វី? | |
| ចុះការកំណត់ថ្លៃវិញ ៖ ខ្ពស់ ឬទាបជាងខ្ញុំ? (សូមផ្តល់ឧទាហរណ៍) | |
| ៣. យោបល់ត្រឡប់ពីគ្រួសារ និងសហសេវិកអាជីវកម្មរបស់អ្នក | |
| តើផលិតផលអ្វីលក់ដាច់ក្នុងអាជីវកម្មរបស់អ្នក (ធៀបនឹង | |

| | |
|---|---|
| អាជីវកម្មស្រដៀងគ្នា)? | |
| តើអ្នកយល់យ៉ាងណាចំពោះអាជីវកម្មរបស់ខ្ញុំ? សូមផ្តល់ជាមតិ។ | |
| តើ<br>អ្នកស្គាល់ពាណិជ្ជករផ្សេងទៀតឬទេ? តើអ្នកយល់យ៉ាងណាពីផលិតផលរបស់ពួកគេ? | |
| តើផលិតផល (របស់ខ្ញុំ) មួយណាដែលមានតម្លៃថ្លៃ ឬថោកខ្លាំង? (ឧទាហរណ៍) | |
| បទពិសោធន៍ដែលខ្ញុំទទួលបានពីយោបល់ត្រឡប់ និងការអង្កេត ៖ | |
| តើខ្ញុំនឹងធ្វើការផ្លាស់ប្តូរអ្វីខ្លះក្នុងអាជីវកម្ម ក្រោយពីការវិភាគនេះ? | |

## ២.៣. ការវិភាគទីផ្សារ ៖ ចំណែកទីផ្សារ និងគូប្រកួតប្រជែង

**ចំណែកទីផ្សារ ៖** ផ្តោតលើវិធីដែលអាចឲ្យគេមើលឃើញ/ស្គាល់ផលិតផលរបស់អ្នក និងកន្លែងលក់ផលិតផលរបស់អ្នក។

- ការលក់តាមផ្ទះ ក្រុមផលិតផល សប្បុរសធម៌ និងព្រឹត្តិការណ៍ថ្ងៃឈប់សម្រាកក្រៅសាលា។ល។

- កន្លែងដែលភ្ញៀវទេសចរណ៍ទៅលេង (ផ្ទះសំណាក់ ហាងកាហ្វេ ប្រាសាទ និងសួនច្បារ)
- តាមប្រៃសណីយ៍ ពេលខ្លះហៅថាការកម្មង់តាមអ៊ីម៉ែលឬអ៊ីនធើរណិត
- អាជីវកម្មជំនាញខ្នាតធំ ដែលមានបណ្តាញទូទាំងសកលលោក និងលក់ផលិតផលស្រដៀងគ្នានឹងអ្នក (អ្នកនឹងក្លាយជាអ្នកផ្គត់ផ្គង់ដល់អាជីវកម្មខ្នាតធំ)

**តម្រូវការ និងចំណង់ចំណូលចិត្តរបស់អតិថិជន ៖** អ្នកត្រូវលក់អ្វី ដែលអតិថិជនត្រូវការ មិនមែនជាអ្វីដែលអ្នកចូលចិត្ត ឬអ្វីដែលអ្នកយល់ថានឹងលក់ដាច់ឡើយ ៖

- អង្កេតពីវត្ថុសិប្បកម្មដែលគូប្រកួតប្រជែងលក់
- សាកសួរអតិថិជនមានស្រាប់ និងអតិថិជនដែលមានសក្តានុពល
- ពិចារណាពីផលិតផលតាមរដូវកាល។ ឧ. ស្រោមដៃ/មួករដូវរំហើយ អាវយឺត ឬកាបូបលុយសម្រាប់ឱកាសបុណ្យចូលឆ្នាំថ្មី
- ម៉ូតជាប្រការសំខាន់។ ឧ. ឆ្នាំនេះ អតិថិជនត្រូវការពណ៌ផ្កាឈូក។ ឆ្នាំក្រោយពួកគេត្រូវការពណ៌ចាស់។ ត្រូវតាមដានក្នុងទស្សនាវដ្តីម៉ូត និងគេហទំព័រសិប្បកម្មអាស៊ី។
- អាយុរបស់អតិថិជន ៖ តើពួកគេជាស្ត្រីអាយុ ១៥-២៥ ឬ ២៥-៤០ ឆ្នាំ?
- យេនឌ័រ និងវប្បធម៌មានឥទ្ធិពលលើអ្វីដែលមនុស្សចូលចិត្ត។ ឧ. ស្ត្រីវ័យក្មេងនៅអាស៊ីចូលចិត្តឈ្មោះម៉ាកមួយចំនួន ដូចជា D&G ចំណែកអ្នកផ្សេងទៀតចូលចិត្តវត្ថុបែបសិប្បកម្ម និងធ្វើដោយដៃ។



**ចំណែកទីផ្សារ**

ឧបករណ៍ខាងក្រោមនឹងជួយអ្នកវិភាគពីចំណែកទីផ្សារ តម្រូវការអតិថិជន និងគូប្រកួតប្រជែងរបស់អ្នក។

| តារាង ២.៣.១ ៖ អតិថិជនសក្តានុពលរបស់ផុមស៊ីទុរី | | | |
|---|---|---|---|
| ចំណែកទីផ្សារ | អតិថិជនសក្តានុពល | តម្រូវការ និងចំណង់ចំណូលចិត្តរបស់អតិថិជន | ការវិភាគគូប្រកួតប្រជែង |
| 1. | បុគ្គល (ម្ចាស់តូបក្នុងផ្សារ) | ស្រាល និងងាយវេចខ្ចប់នៅពេលធ្វើដំណើរ<br>ងាយផ្ញើទៅបរទេស<br>វត្ថុអនុស្សាវរីយ៍នៃដំណើរកំសាន្ត | អ្នកលក់វត្ថុសិប្បកម្មតិចតួចក្នុងទីផ្សារ ឬកន្លែងអាជីវកម្មផ្សេងទៀត។<br>ចំណាយខ្ពស់លើការដឹកជញ្ជូនទំនិញពីប្រទេសផ្សេង (លក់តែក្នុងស្រុក)<br>ពេលវេលាតិចក្នុងការទិញ ចំណាយពេលច្រើនលើអាជីវកម្មសំខាន់ (ឧ.ផ្ទះសំណាក់) |
| 2. | អាជីវកម្មផ្សេងទៀត (ឧ. ផ្ទះសំណាក់ ចំណត ឡានក្រុង ហាងលក់វត្ថុសិប្បកម្មក្នុងស្រុក វិចិត្រសាល និង ហាងកាហ្វេ) | ថ្មីៗនេះ ផ្គត់ផ្គង់ផលិតផលដោយខ្លួនឯង (ចំណាយពេលច្រើន ដោយសារវាមិនមែនជាអាជីវកម្មសំខាន់ ហើយពួកគេមិនអាចចាកចេញពីហាងបាន)<br>ជាទូទៅ ពួកគេមិនស្គាល់កន្លែងស្វែងរកផលិតផល។ | |
| 3. | សាលារៀន សាកលវិទ្យាល័យ (សិស្ស គ្រូបង្រៀន មាតាបិតាដែលរង់ចាំកូនរបស់ខ្លួន) | សិស្សមានពេលជាក់លាក់ក្នុងការទិញផលិតផល និងមានថវិកាតិច។ | មានគូប្រកួតប្រជែងតិចបំផុតក្នុងបរិវេណសាលា។ |

| តារាង ២.៣.២ ៖ ការវិភាគតម្រូវការចំណែកទីផ្សារ | | | |
|---|---|---|---|
| ចំណែកទីផ្សារ | អតិថិជនសក្តានុពល | តម្រូវការ និងចំណង់ចំណូលចិត្តរបស់អតិថិជន | ការវិភាគគូប្រកួតប្រជែង |
| 1. | | | |
| 2. | | | |
| 3. | | | |

## ២.៤. គោលការណ៍ "4 P" នៃការធ្វើទីផ្សារ

### ១. ផលិតផល (Product)

តើអ្នកកំពុងលក់ផលិតផលអ្វីដល់អតិថិជន?

- ប្រភេទ ៖ កាបូប មួក កន្សែងបង់ក ស្រោមដៃ កាបូបលុយ។ល។
- ទំហំ ៖ កាបូបធំ កាបូបតូច កាបូបលុយ ខ្នាតតូច/មធ្យម/ធំ។ល។
- ម៉ូត ៖ ស្ពាយខាងក្រោយ ពាក់លើស្មា យួរដៃ។ល។
- យេនឌ័រ ឬអាយុ ៖ សមស្របសម្រាប់ទារក កុមារ មនុស្សចាស់ បុរស និង/ឬ ស្ត្រី
- គុណភាព ៖ ថោក និងថ្លៃដើមទាប ប្រភេទមធ្យម ថ្លៃ និងថ្លៃដើមខ្ពស់
- ពណ៌ ៖ ចាស់ ខ្ចី ចម្រុះ ទំនើប ប្រពៃណី។ល។
- ការវេចខ្ចប់ ៖ ថង់ផ្សារទំនើបដែលប្រើប្រាស់ឡើងវិញបាន ថង់ក្រដាសដែលបោះពុម្ពជាពិសេស ថង់ក្រណាត់សម្រាប់ផលិតផលថ្លៃៗ ដូចជា គ្រឿងអលង្ការ ។ល។

## ការរៀបរាប់ពីផលិតផល

| តារាង ២.៥.១ ៖ ការរៀបរាប់ពីផលិតផល | | | | | |
|---|---|---|---|---|---|
| | 1: កាបូបលុយធ្វើពីបារអង្គរ | 2: | 3: | 4: | 5: |
| គុណភាព | ប្រើប្រាស់ឡើងវិញ ជាប់ធន់ មិនជ្រាបទឹក | | | | |
| ពណ៌ (សំខាន់/បន្ទាប់បន្សំ) | ក្រែម/ស ការរៀបចំពណ៌ (ចម្រុះ) | | | | |
| ទំហំ/ខ្នាត | 6″ x 3″ | | | | |
| ការវេចខ្ចប់ | មិនមានការវេចខ្ចប់ ឬគម្រប មានតែស្លាកអាជីវកម្ម | | | | |
| ចំណុចលក់លេចធ្លោរ | អាចកែច្នៃឡើងវិញបាន ទាន់សម័យ ថ្លៃដើមទាប មាននិរន្តរភាព ក្នុងស្រុក | | | | |

## គន្លឹះ

- កត់ត្រាពីប្រភេទផលិតផលទាំងអស់។ បំពេញចំណាត់ថ្នាក់ទាំង ៥ នៃផលិតផល (គុណភាព ពណ៌។ល។) សម្រាប់ផលិតផលនីមួយៗ ដូចក្នុងតារាងខាងលើ។
- ត្រូវរៀបរាប់លម្អិត

- ព្យាយាមរក្សាឲ្យទំហំមានលក្ខណៈសាមញ្ញ។ ឧ. រូបអាចមានទំហំតូច មធ្យម ធំ និងធំបំផុត (មានបួនទំហំ)។ ជំនួសឲ្យទំហំ ៨, ១០, ១២, ១៤, ១៦, ១៨, ២០ (៧ ទំហំ) ព្រោះវានឹងបង្កើនបរិមាណស្តុករបស់អ្នក។
- ការវេចខ្ចប់អាចធ្វើឲ្យអតិថិជនភ្ញាក់ផ្អើល និងអាចចំណាយអស់តិចបំផុត។ ឧ. គេអាចនឹងប្រើប្រាស់ក្រដាសវេចខ្ចប់ពណ៌សធម្មតាសម្រាប់វេចខ្ចប់ ស្បោង ដែលមានរូតបិទ និងស្លាកសញ្ញាមួយដែលមានព័ត៌មានទំនាក់ទំនង និងចំណុចលក់លេចធ្លោរក្នុងអាជីវកម្មរបស់អ្នក (ឧ. មាននិរន្តរភាព សរីរាង្គ ជនជាតិ ធ្វើក្នុងស្រុក លាបពណ៌ធម្មជាតិ)។
- តែងតែមានបញ្ហាប្រឈមរវាងគុណភាព និងថ្លៃដើម។ វត្ថុសិប្បកម្មគួរធ្វើឡើងដោយវិចិត្រ និងបំពេញតាមមុខងារបានល្អ។

## ២. ទីកន្លែង

តើអ្នកលក់ផលិតផលឲ្យអតិថិជននៅកន្លែងណា? ដោយរបៀបណា?

- អតិថិជនមកទិញផលិតផលនៅតូប ឬស្តង់របស់អ្នក។
- អ្នកលក់ផលិតផលឲ្យអាជីវកម្មផ្សេង ដែលនឹងមានទំនាក់ទំនងជាមួយភ្ញៀវទេសចរណ៍ និងអ្នកដំណើរ។
- ចុះការកម្មង់តាមប្រៃសណីយ៍វិញ? (ឧ. សម្រាប់អតិថិជនដើរកំសាន្តដែលបានត្រឡប់ទៅផ្ទះវិញ)
- តើអ្នកបានគិតពីការលក់តាមបណ្តាញអ៊ីនធើរណិត ឬហ្វេសប៊ុក ឬទេ? (ការកម្មង់តាមប្រៃសណីយ៍)
- តើទីតាំងណាដែលល្អបំផុតសម្រាប់អតិថិជនរបស់អ្នក?
- តើអតិថិជននឹងទៅកំសាន្តនៅទីណាខ្លះ?
- តើអ្នកអាចដឹកជញ្ជូនផលិតផលទៅតូបបានដែរ ឬទេ?
- តើមានសេវាផ្សេងទៀត ដូចជា ទឹក អគ្គិសនី បន្ទប់ទឹក ឬ បន្ទប់ផ្លាស់សម្លៀកបំពាក់ ឬទេ? (សម្រាប់សាកសម្លៀកបំពាក់ថ្មី)

- តើអ្នកត្រូវពិចារណាពីអ្នកផ្គត់ផ្គង់នៅពេលជ្រើសរើសទីតាំង ឬទេ?
- តើអ្នកនៅតែអាចរកប្រាក់ចំណេញបាន ឬទេ ប្រសិនបើខ្ញុំនៅឆ្ងាយពីអ្នកផលិត?
- តើអ្នកអាចលក់តាមកន្លែងរបស់អ្នកផ្សេងទៀតបានដែរ ឬទេ? (ឧ. ទូក្នុងចំណតឡានក្រុង ការតាំងបង្ហាញលើជញ្ជាំងក្នុងផ្ទះសំណាក់ ឬតូបក្នុងការិយាល័យក្រុង)
- តើការជួលមានតម្លៃប៉ុន្មាន?

**ទីកន្លែង**

**តារាង ២.៤.២ ៖ គំរូជម្រើសទីតាំង**

| | ចំណតឡានក្រុង (ទូ) | ផ្ទះសំណាក់ Lucky's | ផ្សារថ្មើរជើង | | |
|---|---|---|---|---|---|
| ហេតុអ្វី? | អ្នកដំណើរ/ភ្ញៀវទេសចរណ៍តាមឡានក្រុង ផ្គត់ផ្គង់តែប៉ុណ្ណោះ ប្រមូលប្រាក់រៀងរាល់សប្តាហ៍ | អ្នកដំណើរ/ភ្ញៀវទេសចរណ៍ស្នាក់នៅ ផ្គត់ផ្គង់តែប៉ុណ្ណោះ ប្រមូលប្រាក់រៀងរាល់ សប្តាហ៍ | អ្នកដំណើរ/ភ្ញៀវទេសចរណ៍ រក្សាឲ្យខ្ញុំដឹងពីតម្រូវការរបស់អតិថិជន ការប្រើប្រាស់ពេលវេលាបានល្អ | | |
| គុណវិបត្តិ? | បាត់ស្លាក ផលិតផលមួយចំនួនបាត់/ត្រូវបានគេលួច | គ្មាន | ដឹកជញ្ជូន វេចខ្ចប់ រុះរើ យួរ/កាន់ភ្លៀង កម្តៅថ្ងៃ គ្មានអគ្គិសនី | | |
| ថ្លៃដើម / ការជួល ? | គ្មាន។ បង់កម្រៃជើងសារ (៥% នៃទំនិញលក់) | គ្មាន។ ពួកគេគាំទ្រអាជីវកម្មក្នុងស្រុក | $5 សម្រាប់តូបតូច £10 សម្រាប់តូបធំ | | |

| តារាង ២.៤.៣ ៖ គំរូឯកសារជម្រើសទីតាំង | | | | | |
|---|---|---|---|---|---|
| តើទីតាំងនោះ ៖<br>❑ ជួល ❑ ជាម្ចាស់ ❑ ជួលបន្ត ❑ លក់/សេង ❑ ផ្សេងៗ | | | | | |
| | 1. | 2. | 3. | 4. | 5. |
| ហេតុអ្វី? | | | | | |
| គុណវិបត្តិ? | | | | | |
| ថ្លៃដើម/ ការជួល? | | | | | |

**គន្លឹះ**

- ពិចារណា រួចវាយតម្លៃពីកន្លែងជាច្រើន សាកសួរមិត្តភក្តិ ទៅកាន់ផ្ទះសំណាក់ ហាងកាហ្វេ ហាងលក់វត្ថុសិប្បកម្មផ្សេងទៀត
- ពិចារណាពីពេលវេលារបស់អ្នក។ អ្នកមិនអាចស្ថិតនៅក្នុងកន្លែងលើសពីមួយ ក្នុងពេលតែមួយបានឡើយ។ អ្នកអាចជួលនរណាម្នាក់ឲ្យនៅកន្លែងមួយ ប៉ុន្តែអ្នកនៅតែត្រូវទូទាត់សម្រាប់ពេលវេលារបស់ពួកគេ។
- ការលក់តាមភាគីទី ៣ (ឧ. ចំណតឡានក្រុង ហាងកាហ្វេ) តែងតែជាវិធីដែលមានប្រសិទ្ធភាពចំណាយ។ ជាទូទៅ អ្នកគ្រាន់តែបង់កម្រៃជើងសារ ឬភាគរយនៃផលិតផលលក់ប៉ុណ្ណោះ។
- ពាណិជ្ជករទីផ្សារ និងតាមដងផ្លូវត្រូវមានសុខភាពល្អ។ ពួកគេត្រូវយួរ/កាន់វត្ថុធ្ងន់ៗជាច្រើន និងត្រូវធ្វើការក្រោមកម្តៅថ្ងៃ។ ត្រូវញ៉ាំទឹកឲ្យបានច្រើនក្នុងរដូវក្តៅ។
- របៀបតាំងបង្ហាញផលិតផលរបស់អ្នក ៖ ប្រើប្រាស់ក្រណាត់តុដែលស្អាត

និងធម្មតា។ ព្យួរ បត់ និងលើកវត្ថុមួយចំនួនឡើង (ឧ. ប្រើប្រអប់ដាក់ក្រោមក្រណាត់)។ ដាក់កញ្ចក់ឆ្លុះ សម្រាប់គ្រឿងអលង្ការ។

## ៣. ការផ្សព្វផ្សាយ

តើអ្នកនឹងអាចឲ្យអតិថិជនស្គាល់ផលិតផលរបស់អ្នកដោយរបៀបណា? តើអ្នកនឹងជំរុញពួកគេឲ្យទិញដោយរបៀបណា?

- អ្នកអាចប្រើប្រាស់សញ្ញានៅតូបសំខាន់របស់អ្នក (ឧ. ម៉ោងបិទ និងបើក លេខទូរស័ព្ទ ឈ្មោះរបស់អ្នក ឈ្មោះអាជីវកម្ម និងអ៊ីម៉ែល)។
- តើអ្នកពន្យល់លើប័ណ្ណអាជីវកម្ម ប័ណ្ណព័ត៌មាន ឬស្លាក ពីដើមកំណើតផលិតផលរបស់អ្នក និងរបៀបដែលអ្នកកំពុងគាំទ្រអ្នកផលិតក្នុងមូលដ្ឋាន និងជំរុញវប្បធម៌ និងសិប្បកម្មជនជាតិ ឬទេ?
- តើអ្នកមានការជូនដំណឹង ឬប័ណ្ណព័ត៌មានដែលបង្ហាញពីការបញ្ចុះតម្លៃសម្រាប់ការទិញចាប់ពី ១០ នៃផលិតផលតែមួយ ឬការលើកទឹកចិត្ត ដូចជា "ទិញ ២ ថែម ១" ឬទេ?
- ចុះការធានាគុណភាពវិញ?



**ការផ្សព្វផ្សាយ**

| តារាង ២.៤.៤ ៖ ការផ្សាយពាណិជ្ជកម្ម | | |
|---|---|---|
| ប្រភេទ | ព័ត៌មានលម្អិត | ថ្លៃដើម |
| សញ្ញាសម្រាប់តូបក្នុងផ្សារ | អ្នករចនាស្លាកដែលមានឈ្មោះអាជីវកម្ម ម្ចាស់ លេខទូរស័ព្ទ | $30 |
| ប័ណ្ណអាជីវកម្ម | ដូចខាងលើដែរ ប៉ុន្តែរាប់បញ្ចូល USP (ឧ. មាននិរន្តរភាព ក្នុងស្រុក ធ្វើដោយដៃ។ល។) | $12 |
| ស្លាកផលិតផល | ស្លាកតូចស្អិតដែលអាចបកចេញបានលើសំបកវេចខ្ចប់មានឈ្មោះ និងលេខទូរស័ព្ទ | $5 |

| | | |
|---|---|---|
| | | |
| | | |
| | | |
| ការផ្សព្វផ្សាយ | | |
| ប្រភេទ | ព័ត៌មានលម្អិត | ថ្លៃដើម |
| ការបញ្ចុះតម្លៃតាមរដូវកាល | បញ្ចុះតម្លៃ ១០% សម្រាប់ទិវាបុណ្យម្តាយ បញ្ចុះតម្លៃ ២០% សម្រាប់ការលក់លាងឃ្លាំងរដូវរំហើយ | ១០% នៃប្រាក់ចំណូលសម្រាប់អំឡុងពេលដូចគ្នា |
| ទិញដុំ | បញ្ចុះតម្លៃ ២០% សម្រាប់ការទិញផលិតផលតែមួយចាប់ពី ៥ ឡើងទៅ ផ្ញើតាមប្រៃសណីយ៍ដោយឥតគិតថ្លៃសម្រាប់ការទិញលើសពី ១០០ ដុល្លា | ថ្លៃផ្ញើតាមប្រៃសណីយ៍ ២ ដុល្លា/១០០<br>១/៥ |
| ទិញ ២ ថែម ១<br>(រាល់ពេល) | គ្រប់ពេលទាំងអស់ រាប់ទាំង ពេលមានតម្រូវការទាបរដូវភ្លៀង បុណ្យចូលឆ្នាំចិន | ១/៣ |
| | | |
| | | |
| | | |

**គន្លឹះ**

- ការផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយមានលក្ខណៈស្រដៀងគ្នា។ ការផ្សាយពាណិជ្ជកម្មគឺការលក់តាមរយៈការបង្ហាញប្រាប់ ចំណែកការផ្សព្វផ្សាយអាចជាការលក់ក្នុងទម្រង់ជាការផ្តល់ជូនពិសេស។
- អ្នកគួរផ្តល់ព័ត៌មានដល់អតិថិជនស្តីពីផលិតផល និងចំណុចលក់លេចធ្លោររបស់អ្នក ដាក់ព័ត៌មានលើសញ្ញា និងមានស្លាកតូចមួយបោះភ្ជាប់ ដើម្បីឲ្យអ្នកភ្ជាប់ជាមួយគ្នា។
- អ្នកអាចបង់ប្រាក់ (ឬព្យាយាមទទួលបានដោយមិនអស់ប្រាក់) សម្រាប់ការផ្សាយពាណិជ្ជកម្មក្នុងកាសែត ទស្សនាវដ្ដី ឬតាមវិទ្យុ។ ក្រៅពីនេះ អ្នកអាចធ្វើឲ្យការផ្សាយពាណិជ្ជកម្មរបស់អ្នកក្លាយជាព្រឹត្តិការណ៍ព័ត៌មាន (ឧ. ទីតាំងថ្មី)។
- ម្យ៉ាងទៀត អ្នកអាចបង់ប្រាក់សម្រាប់ការផ្សាយពាណិជ្ជកម្មផ្សព្វផ្សាយនៅពេលអ្នកមានការផ្តល់ជូនថ្មីៗ។ ត្រូវដឹងថា អ្នកត្រូវចំណាយប្រាក់សម្រាប់សកម្មភាពនេះ។ បណ្តាញ និងការនិយាយតាមគ្នាអាចល្អប្រសើរជាង។
- ព្យាយាមតាមដាន និងកត់ត្រាការផ្សព្វផ្សាយ និងការផ្សាយពាណិជ្ជកម្មដើម្បីឲ្យអ្នកដឹងពីការខាតបង់ ឬការចំណេញ។ យ៉ាងហោចណាស់ អ្នកគួរផ្តោតលើចំណាយក្នុងការផ្សព្វផ្សាយ/ការផ្សាយពាណិជ្ជកម្ម។

## ៤.ថ្លៃ

តើអ្នកនឹងកំណត់ថ្លៃប៉ុន្មាន? ថ្លៃមានសារៈសំខាន់បំផុត។ ប្រសិនបើកំណត់ខ្ពស់ពេក អ្នកនឹងលក់មិនដាច់ ប៉ុន្តែប្រសិនបើកំណត់ទាបពេក អ្នកនឹងមិនបានប្រាក់ចំណេញឡើយ។ ការកំណត់ថ្លៃមានក្នុងផ្នែកទី ៤។



# ការរៀបចំថវិកា និងការកំណត់ថ្លៃ

## ៣. ការរៀបចំថវិកា និងការកំណត់ថ្លៃ

គោលបំណង ៖

- ជួយអ្នកឲ្យយល់ពីរបៀបគ្រប់គ្រងលំហូរហិរញ្ញវត្ថុ និងរបៀបកំណត់ថ្លៃ
- យល់ពីចំណាយខុសៗគ្នា និងរបៀបគណនាប្រាក់ចំណេញ
- ផ្តល់ឧបករណ៍ជាច្រើនសម្រាប់កត់ត្រាលំហូរហិរញ្ញវត្ថុ។

សៀវភៅណែនាំវគ្គបណ្តុះបណ្តាល ៖

- ផ្នែកនេះមានក្នុងវគ្គបណ្តុះបណ្តាលទី ៤។

ប្រាក់គឺជាគន្លឹះនៃអាជីវកម្មរបស់អ្នក។ មានចំណុចជាច្រើនដែលត្រូវលើកឡើងក្នុងផែនការសកម្មភាពខាងក្រោមដើម្បីធានាថា អ្នកកំពុងដំណើរការអាជីវកម្មដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

- ប្រាក់សម្រាប់អាជីវកម្មត្រូវរក្សាទុកដោយឡែកពីប្រាក់ផ្ទាល់ខ្លួន
- តម្លៃលក់របស់អ្នកត្រូវរាប់បញ្ចូលចំណាយទូទៅក្នុងអាជីវកម្ម ដូចជា ការជួល ប្រាក់ឈ្នួល វត្ថុធាតុ។ល។
- រក្សាឲ្យចំណាយថេរនៅទាប ព្រោះវាជាឧបសគ្គក្នុងអាជីវកម្ម។ ចំណាយអថេរនឹងផ្លាស់ប្តូរទៅតាមទំហំនៃការលក់។ ទោះបីចំណាយអថេរមានសារៈសំខាន់ ប៉ុន្តែវាមិនសូវបង្កបញ្ហាដល់ប្រាក់ចំណេញរួមឡើយ។
- កត់ត្រាប្រតិបត្តិការសាច់ប្រាក់របស់អ្នកជារៀងរាល់ថ្ងៃ និងវាយតម្លៃរៀងរាល់ខែ។

**និយមន័យ**

មិនមាននិយមន័យសាមញ្ញនៃការរៀបចំថវិកាឡើយ ព្រោះមានពាក្យពេចន៍ជាច្រើនត្រូវបានប្រើប្រាស់ក្នុងអាជីវកម្មសម្រាប់ការគ្រប់គ្រងសាច់ប្រាក់។ យ៉ាងនេះក្តី យើងអាចរក្សាឲ្យវាមានលក្ខណៈសាមញ្ញ ដោយប្រើប្រាស់បច្ចេកទេសកត់ត្រាចូលបញ្ជី

មូលដ្ឋាន និងឯកសារគំរូ រួមទាំងចំណុចសំខាន់ៗខាងក្រោម ៖

- បញ្ជីសាច់ប្រាក់
- ឯកសារវិក្កយបត្រលក់
- ឯកសារវិក្កយបត្រទិញ
- បញ្ជីចំណាយ
- បញ្ជីសាច់ប្រាក់បន្ទាប់បន្សំ

### តារាងផ្ទៀងផ្ទាត់

តារាងផ្ទៀងផ្ទាត់នេះ នឹងផ្តល់ផែនទីចង្អុលបង្ហាញផ្លូវសម្រាប់ការបង្កើតប្រព័ន្ធផ្ទាល់ខ្លួននៃការកត់ត្រាចូលបញ្ជី។ អ្នកអាចបំពេញតារាងនេះ នៅពេលបានអានពីឧបករណ៍សំខាន់ៗ។

តារាងទី ៣ ៖ តារាងផ្ទៀងផ្ទាត់ប្រព័ន្ធហិរញ្ញវត្ថុ

| | លាយលក្ខណ៍អក្សរ? | ត្រូវកែលម្អ (បាទ/ចាស/ទេ) | អ្នកទទួលខុសត្រូវ | ពេលវេលា |
|---|---|---|---|---|
| ថ្លៃផលិតផល | | | | |
| ថ្លៃលក់ | | | | |
| ចំណាយ (ថេរ និងអថេរ) | | | | |
| ប្រាក់ចំណេញ | | | | |
| បញ្ជីសាច់ប្រាក់ | | | | |
| វិក្កយបត្រលក់ | | | | |
| វិក្កយបត្រទិញ | | | | |
| ចំណាយ និង បង្កាន់ដៃ | | | | |

| | | | | |
|---|---|---|---|---|
| សាច់ប្រាក់បន្ទាប់បន្សំ | | | | |
| ការគ្រប់គ្រងស្តុក | | | | |
| សម្គាល់ ៖ | | | | |

## ៣.១. ការប៉ាន់ស្មានថ្លៃផលិតផល និងការលក់ប្រចាំខែ

អ្នកមិនអាចទទួលបានជោគជ័យក្នុងការព្យាយាមគ្រប់គ្រង ឬកែលម្អអាជីវកម្មរបស់អ្នកឡើយ ប្រសិនបើអ្នកមិនគ្រប់គ្រងសាច់ប្រាក់។ ការគ្រប់គ្រងប្រតិបត្តិការអាជីវកម្មដោយប្រសិទ្ធភាព មានន័យថា អ្នកដឹងពីព័ត៌មានហិរញ្ញវត្ថុលម្អិតក្នុងអាជីវកម្មនៅគ្រប់ពេលទាំងអស់ ដូចជា ៖

- តើអ្នកបានទិញផលិតផលប៉ុន្មានពីអ្នកផ្គត់ផ្គង់?
- តើអ្នកកំណត់ថ្លៃប៉ុន្មានពីអតិថិជន?
- តើអ្នកមានទ្រព្យសកម្មអ្វីខ្លះ? (ឧ. ទិញពីអ្នកផ្គត់ផ្គង់ ប៉ុន្តែមិនមែនលក់នោះទេ និងហៅថា ស្តុក)
- ថាតើអ្នកកំណត់ថ្លៃគ្រប់គ្រាន់សម្រាប់ផលិតផលរបស់អ្នកដើម្បីទទួលបានប្រាក់ចំណេញ ក្រោយពីបានទូទាត់ចំណាយក្នុងអាជីវកម្ម ឬយ៉ាងណា។

កិច្ចការដំបូងរបស់យើង គឺត្រូវស្វែងយល់ថាតើអាជីវកម្មទទួលបានប្រាក់ចំណេញ ឬយ៉ាងណា ឬយ៉ាងហោចណាស់រាប់បញ្ចូលចំណាយក្នុងអាជីវកម្មទាំងអស់។ ដើម្បីសម្រេចកិច្ចការនេះ យើងត្រូវពិនិត្យថ្លៃផលិតផលធៀបនឹងការលក់ និងចំណាយរបស់យើង ដោយប្រើប្រាស់ឧបករណ៍ខាងក្រោម ៖

- ការប៉ាន់ស្មានថ្លៃផលិតផល
- ការប៉ាន់ស្មានការលក់ផលិតផលប្រចាំខែ

- ថ្លៃដើមវត្ថុធាតុដើម (អថេរ)
- ចំណាយលើកម្លាំងពលកម្ម (អថេរ)
- ចំណាយថេរ (រួមបញ្ចូលចំណាយទូទៅ)
- ចំណាយសរុប/ខែ
- ថ្លៃ x ការលក់ - ចំណាយ = ប្រាក់ចំណេញ

## ១. ការប៉ាន់ស្មានថ្លៃផលិតផល

[១០ នាទី] តើអ្នកនឹងកំណត់ថ្លៃប៉ុន្មានសម្រាប់អតិថិជន? ដើម្បីបានប្រាក់ចំណេញ ថ្លៃដែលសមស្របសម្រាប់អតិថិជន ត្រូវខ្ពស់ជាងចំណាយរបស់អ្នក និងធៀបនឹងថ្លៃរបស់គូប្រកួតប្រជែង។ ដើម្បីកំណត់ថ្លៃ អ្នកត្រូវដឹងពី ៖

- ថ្លៃសមស្របសម្រាប់អតិថិជនសក្តានុពលរបស់អ្នក
- ថ្លៃរបស់គូប្រកួតប្រជែង ៖ ខ្ពស់បំផុត និងទាបបំផុតក្នុងទីផ្សារសម្រាប់ផលិតផលប្រភេទតែមួយ
- ចំណាយរបស់អ្នកក្នុងការដឹកជញ្ជូនផលិតផលទៅចំណុចលក់ ដូចជា ទីផ្សារ។

## ២. ការប៉ាន់ស្មានការលក់ប្រចាំខែ

នៅពេលអ្នកបានប៉ាន់ស្មាន អ្នកអាចគណនាការលក់ប្រចាំខែបាន។ អ្នកអាចសម្រេចគោលដៅនេះតាមវិធីជាច្រើន ៖

- ការប្រៀបធៀបនឹងតួលេខលក់សម្រាប់អំឡុងពេលតែមួយកាលពីឆ្នាំមុន
- ការប្រៀបធៀបនឹងអ្នកលក់វត្ថុសិប្បកម្មផ្សេងទៀត
- ការអង្កេតជាមួយអតិថិជនសក្តានុពល
- ការសាកល្បងតាមមូលដ្ឋាន ដោយមានប្រភេទផលិតផលមួយចំនួនតូចសម្រាប់សាកល្បង ៖ អ្វីដែលលក់ដាច់ដាច់ បរិមាណ។ល។ (នេះមិនមែនជាវិធីល្អឡើយ ប្រសិនបើត្រូវចំណាយខ្ពស់)
- ការកម្មង់ទុកមុន ៖ កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរតែងតែល្អជាងការព្រមព្រៀងជាពាក្យសំដី។

## ការប៉ាន់ស្មានថ្លៃ និងការលក់

| តារាង ៣.១.១ ៖ គំរូការប៉ាន់ស្មានថ្លៃផលិតផល | | | |
|---|---|---|---|
| | 1: កាបូបលុយធ្វើពីបាវអង្ករ | 2: | 3: |
| ថ្លៃសមស្របសម្រាប់អតិថិជន | $1.50 | | |
| ថ្លៃខ្ពស់បំផុត និងទាបបំផុតរបស់គូប្រកួតប្រជែង | $2.25 (លក់ក្នុងហាងទីក្រុង)<br>$1.25 (លក់តាមផ្ទះ) | | |
| ថ្លៃរបស់ខ្ញុំ (មុនពេលបញ្ចុះតម្លៃ) | $1.50 | | |

| តារាង ៣.១.២ ៖ ការប៉ាន់ស្មានថ្លៃផលិតផល | | | |
|---|---|---|---|
| | 1: | 2: | 3: |
| ថ្លៃសមស្របសម្រាប់អតិថិជន | | | |
| ថ្លៃខ្ពស់បំផុត និងទាបបំផុតរបស់គូប្រកួតប្រជែង | | | |
| ថ្លៃរបស់ខ្ញុំ (មុនពេលបញ្ចុះតម្លៃ) | | | |

| តារាង ៣.១.៣ ៖ គំរូនៃការប៉ាន់ស្មានការលក់ប្រចាំខែ | | | | | |
|---|---|---|---|---|---|
| ខែ | ផលិតផលទី ១ | ផលិតផលទី ២ | ផលិតផលទី ៣ | ផលិតផលទី ៤ | ផលិតផលទី ៥ |
| 1 | 80 | | | | |
| 2 | 90 | | | | |
| 3 | 100 | | | | |
| 4 | 150 | | | | |
| 5 | 100 | | | | |
| 6 | 100 | | | | |
| សរុប (ក្នុងរយៈពេល ៦ ខែ) | 620 | | | | |
| មធ្យមភាគប្រចាំខែ | 104 | | | | |

| តារាង ៣.១.៤ ៖ ការប៉ាន់ស្មានការលក់ប្រចាំខែ | | | | | |
|---|---|---|---|---|---|
| ខែ | ផលិតផលទី ១ | ផលិតផលទី ២ | ផលិតផលទី ៣ | ផលិតផលទី ៤ | ផលិតផលទី ៥ |
| 1 | | | | | |
| 2 | | | | | |
| 3 | | | | | |
| 4 | | | | | |
| 5 | | | | | |
| 6 | | | | | |
| សរុប (ក្នុង | | | | | |

| | | | | | |
|---|---|---|---|---|---|
| រយៈពេល ៦ ខែ) | | | | | |
| មធ្យមភាគប្រចាំខែ | | | | | |

**គន្លឹះ**

- សកម្មភាពនេះអាចពិបាក នៅពេលអ្នកចាប់ផ្តើមអាជីវកម្មថ្មី ព្រោះអ្នកនឹងត្រូវមានការប៉ាន់ស្មានមួយចំនួន មុនពេលអ្នកបន្តទៅជំហានបន្ទាប់។ វាអាចជាប្រការចាំបាច់ក្នុងការបន្ថែម ៥%-១០% លើការប៉ាន់ស្មានរបស់អ្នកដើម្បីបញ្ចូលការខាតបង់ផលិតផល (ឧ. ការបំផ្លាញដោយទឹក ចោរលួច។ល។) ឬការលក់ខ្ពស់។
- ការលក់មធ្យម (សរុប ៦ ខែចូលគ្នា បន្ទាប់មកចែកនឹង ៦ ដើម្បីបានមធ្យមភាគ) ព្រោះនៅពេលអាជីវកម្មលូតលាស់ ការលក់នឹងកើនឡើង។
- អាជីវកម្មមួយចំនួនមានលក្ខណៈតាមរដូវកាល មានន័យថា ពួកគេនឹងលក់បានតិច ឬច្រើនទៅតាមពេលវេលាក្នុងឆ្នាំ។ មនុស្សទិញវត្ថុសិប្បកម្ម នៅពេលពួកគេឈប់សម្រាក។ ធាតុអាកាសក៏ចោទជាបញ្ហាដែរ ព្រោះមនុស្សមិនចង់ចេញក្រៅឡើយ នៅពេលមានភ្លៀងខ្លាំង។

## ៣.២. ដឹងពីចំណាយរបស់អ្នក

### ចំណាយថេរ និងចំណាយអថេរ = ចំណាយសរុប

ឥឡូវនេះ អ្នកដឹងពីបរិមាណផលិតផលដែលនឹងត្រូវលក់ចេញ និងការប៉ាន់ស្មានពីថ្លៃលក់ ប៉ុន្តែអ្នកមិនអាចបញ្ជាក់តួលេខទាំងនេះឡើយ រហូតទាល់តែអ្នកគណនាចំណាយលើការលក់ផលិតផល ដែលមានប្រភេទចំណាយផ្សេងៗជាច្រើន។ ចំណាយរបស់អ្នកអាចថេរ ឬអថេរ។ ចំណាយថេរមិនផ្លាស់ប្តូរតាមបរិមាណលក់ឡើយ។ ប្រសិនបើអ្នកលក់មិនដាច់ (ឧ. មានភ្លៀង ហើយអ្នកមិនអាចបើកតូបបាន) អ្នកនៅតែត្រូវទូទាត់ចំណាយថេរ។ ចំណាយអថេរ (រាប់បញ្ចូលថ្លៃដើម

វត្ថុធាតុដើម និងកម្លាំងពលកម្ម) គឺខុសពីនេះ។ អ្នកត្រូវទូទាត់តែនៅពេលលក់ដាច់ប៉ុណ្ណោះ (ឧ. ការវេចខ្ចប់ផលិតផល)។

| តារាង ៣.២.១ ៖ និយមន័យចំណាយ | |
|---|---|
| ពាក្យគន្លឹះ | **និយមន័យ** |
| ចំណាយអថេរ | ចំណាយអថេរប្រែប្រួលទៅតាមបរិមាណលក់ និងរួមបញ្ចូលថ្លៃដើមវត្ថុធាតុដើម និងកម្លាំងពលកម្ម។ អ្នកលក់វត្ថុសិប្បកម្មនឹងបញ្ចូលចំណាយដូចជា ការដឹកជញ្ជូន និងការផ្ញើផលិតផលតាមប្រៃសណីយ៍ឲ្យអតិថិជន។ល។ ឧ. ការហៅទូរស័ព្ទជាចំណាយអថេរ ប៉ុន្តែមិនមែនលើទូរស័ព្ទឡើយ ព្រោះចំណាយនេះប្រែប្រួលទៅតាមភាពញឹកញាប់ និងរយៈពេលនៃការហៅទូរស័ព្ទ។ |
| វត្ថុធាតុដើម | សំដៅលើវត្ថុធាតុចាំបាច់សម្រាប់ផលិតផលិតផលចុងក្រោយ។ ឧ. សំបកវេចខ្ចប់គ្រឿងអលង្ការ ឬស្លាកសម្រាប់ផលិតផល។ វត្ថុធាតុដើមចាត់ទុកជាចំណាយអថេរ ព្រោះវាប្រែប្រួលទៅតាមបរិមាណផលិតផលលក់។ |
| ចំណាយលើកម្លាំងពលកម្ម | ចំណាយលើកម្លាំងពលកម្មគឺប្រាក់ឈ្នួលដែលអ្នកបង់ឲ្យខ្លួនឯង និយោជិត ឬកម្រៃជើងសារដែលបើកឲ្យអ្នកលក់ (ឧ. អ្នកគ្រប់គ្រងទូក្នុងចំណតឡានក្រុង)។ ចំណាយលើកម្លាំងពលកម្មចាត់ទុកជាចំណាយអថេរ ព្រោះវាប្រែប្រួលទៅតាមអ្វីដែលអ្នកលក់ (ឧ. អ្នកគ្រប់គ្រងទូ ៖ មិនទទួលបានប្រាក់ឈ្នួលទៀងទាត់ ប៉ុន្តែទទួលបានភាគរយពីការលក់)។ ដូចគ្នានេះដែរ ប្រាក់ឈ្នួលរបស់អ្នកគួរអាស្រ័យលើប្រសិទ្ធភាពការងាររបស់អ្នក។ |
| ចំណាយថេរ | ចំណាយថេរនៅដដែល ដោយមិនអាស្រ័យនឹងបរិមាណលក់ឡើយ។ ឧ. ចំណាយលើការជួលតូបក្នុងផ្សាររាត្រីថ្ងៃសៅរ៍ ទូរស័ព្ទ។ល។ |

| តារាង ៣.២.២ ៖ ចំណាយថេរ និងចំណាយអថេរ | | |
|---|---|---|
| ផ្នែក/មុខ | **អថេរ** | **ថេរ** |
| ការជួលតូបប្រចាំខែ | | ✓ |
| កម្រៃជើងសារសម្រាប់ទូក្នុងចំណាតឡានក្រុង | ✓ | |
| ការទូទាត់ប្រាក់កម្ចីលើការទិញម៉ូតូ | | ✓ |
| កាហ្វេសម្រាប់បុគ្គលិក | | ✓ |
| អគ្គិសនីក្នុងតូប | | ✓ |
| កាតទូរស័ព្ទ | | ✓ |
| ផលិតផលសម្អាត | ✓ | |
| ប្រៃសណីយ៍ និងការវេចខ្ចប់ផលិតផលសម្រាប់ផ្ញើទៅបរទេស | | ✓ |
| ការទូទាត់សន្តិសុខសង្គមរបស់ម្ចាស់អាជីវកម្ម | | ✓ |
| ការទូទាត់ប្រាក់ខ្ចីពីលោកពូ | | ✓ |
| ការទូទាត់ថ្ងៃឈប់សម្រាកសម្រាប់ម្ចាស់អាជីវកម្ម | | ✓ |
| ចំណាយលើការដឹកជញ្ជូនដើម្បីប្រមូលផលិតផលតាមភូមិ | | |

| | | |
|---|---|---|
| ចំណាយលើកន្លែងស្នាក់នៅដើម្បីអង្កេតពិពណ៌ពាណិជ្ជកម្មវត្ថុសិប្បកម្មក្នុងទីក្រុង | | ✓ |
| កម្រាលតុថ្មីក្នុងតូប | | ✓ |
| កន្ត្រៃ | | ✓ |
| សញ្ញាថ្មីសម្រាប់ទូតាំង | | ✓ |
| ប័ណ្ណអាជីវកម្មដែលមានស្លាក | | ✓ |
| ប្រអប់ជ័រមានគម្របដើម្បីដឹកជញ្ជូនផលិតផលទៅផ្សារ | | ✓ |
| ការវេចខ្ចប់ផលិតផល | ✓ | |

**កំណត់សម្គាល់**

ត្រូវរក្សាចំណាយផ្ទាល់ខ្លួនចេញពីគណនីអាជីវកម្ម។ ឧ. ម្ចាស់អាជីវកម្មទិញរ៉ូបថ្មីមួយពីតូបក្នុងទីផ្សារ និងដកប្រាក់ចេញពីធុងប្រាក់របស់គាត់។ នេះមិនមែនជាការអនុវត្តល្អឡើយ ប្រសិនបើអ្នកមិនបានកត់ត្រា និងទូទាត់សងវិញ។ ការទូទាត់សន្តិសុខសង្គម និងពន្ធលើអាជីវកម្មគួរដកចេញពីគណនីអាជីវកម្មសម្រាប់ម្ចាស់អាជីវកម្ម និងនិយោជិតពេញម៉ោង។

## ចំណាយអថេរ ៖ វត្ថុធាតុដើម

| តារាង ៣.២.៣ ៖ ចំណាយអថេរ (វត្ថុធាតុដើម) | | | |
|---|---|---|---|
| វត្ថុធាតុដើម | បរិមាណ | ថ្លៃ/ឯកតា | ចំណាយ/ផលិតផល |
| ស្បោងពណ៌ត្នោត មានបោះពុម្ពស្លាក | 1 | $10 សម្រាប់ 100 | $0.10 |
| ស្លាកបកបិទ | 1 | $5 សម្រាប់ 100 | $0.05 |
| ចំណាយសរុបលើផលិតផលមួយ | $0.15 | | |
| សរុប/ខែ | 18.8 (យកចេញពីការគណនាពីមុន) | | |
| ចំណាយ/ខែ | $2.28 សម្រាប់ចំណាយអថេរលើវត្ថុធាតុដើម | | |

តារាង ៣.២.៤ ៖ ចំណាយអថេរ (វត្ថុធាតុដើម)

| វត្ថុធាតុដើម | បរិមាណ | ថ្លៃ/ឯកតា | ចំណាយ/ផលិតផល |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| ចំណាយសរុបលើផលិតផលមួយ | | | |
| សរុប/ខែ | | | |
| ចំណាយ/ខែ | | | |

**គន្លឹះ**

- រក្សាកំណត់ត្រាចំណាយទាំងនេះ
- ប្រសិនបើអ្នកអាចទៅទិញវត្ថុធាតុផលិតផលនៅទីផ្សារបាន (ឧ. បាវអង្ករ) អ្នកអាចផ្តល់ចំណាយសម្រាប់អ្នកផលិតបាន (សិប្បករ)។ ត្រូវដឹងពីចំណាយផលិតកម្ម និងចរចា
- ពិនិត្យ និងទទួលបានសម្រង់តម្លៃសម្រាប់វត្ថុថ្លៃៗដែលអ្នកត្រូវទិញ សុំបញ្ចុះតម្លៃសម្រាប់ការទិញដុំ
- សរសេរ ឬគូរអ្វីដែលអ្នកចង់ផលិត ឬបោះពុម្ព (សញ្ញា ប័ណ្ណព័ត៌មាន ស្លាក)។ ដូច្នេះ ប្រសិនបើមានកំហុស អ្នកមិនចាំបាច់ទូទាត់សងឡើយ។ ឧ. ប្រសិនបើសញ្ញាហាងខុសលេខទូរស័ព្ទ។

**ចំណាយអថេរ ៖ កម្លាំងពលកម្ម**

| តារាង ៣.២.៥ ៖ ចំណាយអថេរ (កម្លាំងពលកម្ម/ប្រាក់ឈ្នួល) | | | |
|---|---|---|---|
| នរណាខ្លះ? | ក្នុងមួយខែ | អត្រា | ចំណាយ/ខែ |
| ខ្ញុំ | 5 ម៉ោង/ថ្ងៃ x 6 ថ្ងៃ/សប្តាហ៍ x 4 សប្តាហ៍/ខែ = 120 ម៉ោង | $1 /ម៉ោង | $120 |
| អ្នកគ្រប់គ្រងទូក្នុងចំណតឡានក្រុង | ប៉ាន់ស្មានការលក់ 10/ខែនៃផលិតផលដែលមានតម្លៃ $1.5 (ចេញពីការគណនាពីមុន) = $15 | 10% នៃទំនិញលក់ | $1.50 |
| ចំណាយអថេរលើកម្លាំងពលកម្ម/ខែ | | | |

តារាង ៣.២.៦ ៖ ចំណាយអថេរ (កម្លាំងពលកម្ម/ប្រាក់ឈ្នួល)

| នរណាខ្លះ? | ក្នុងមួយខែ | អត្រា | ចំណាយ/ខែ |
|---|---|---|---|
| ខ្ញុំ | | | |
| បុគ្គលិក | | | |
| ចំណុចលក់ទី ១ | | | |
| ចំណុចលក់ទី ២ | | | |
| ចំណុចលក់ទី ៣ | | | |
| ចំណាយ/ខែ | | | |

**គន្លឹះ**

- ភាគរយសម្រាប់អ្នកគ្រប់គ្រងទូចំណតឡានក្រុង អាចបញ្ចូលជាការគណនាចំណាយលើវត្ថុធាតុដើម ប៉ុន្តែវាគួរចាត់ទុកជាចំណាយលើកម្លាំងពលកម្ម។ តាមវិធីណាក៏ដោយ វានៅតែជាចំណាយអថេរ។
- រក្សាប្រាក់ឈ្នួលរបស់អ្នកឲ្យនៅទាប នៅពេលអ្នកបង្កើតអាជីវកម្មថ្មី និងនៅពេលដែលអ្នកពង្រីកអាជីវកម្មទៅក្នុងតំបន់ ឬដំណាក់កាលថ្មី។
- បុគ្គលិកទទួលបានប្រាក់ឈ្នួលតាមម៉ោង គឺល្អសម្រាប់អាជីវកម្មជាងប្រាក់បៀវត្សរ៍ប្រចាំខែ ព្រោះអ្នកគ្រាន់តែទូទាត់នៅពេលធ្វើការប៉ុណ្ណោះ។
- នៅពេលអ្នកបង្កើតអាជីវកម្ម ហើយអ្នកចាប់ផ្ដើមទទួលបានប្រាក់ចំណេញ សូមពិចារណាពីការផ្ដល់ប្រាក់បៀវត្សរ៍ដល់បុគ្គលិកស្មោះត្រង់។ អ្នកនឹងទទួលខុសត្រូវលើការផ្ដល់ការទូទាត់សម្រាប់ថ្ងៃឈប់សម្រាក និង

អត្ថប្រយោជន៍ការងារផ្សេងទៀត (ឧ. សុខភាព សន្តិសុខសង្គម សម្រាកមាតុភាព។ល។) ប៉ុន្តែអ្នកនឹងធ្វើរឿងត្រឹមត្រូវ ហើយពួកគេនឹងកាន់តែធ្វើការដោយប្រសិទ្ធភាព។ ក្រៅពីនេះ អ្នកអាចពិចារណាពីប្រាក់ឈ្នួលគោលតាមខែដោយមានភាគរយកម្រៃជើងសារសម្រាប់ផលិតផលដែលលក់ដាច់។

**ចំណាយថេរ**

| តារាង ៣.២.៧ ៖ ចំណាយថេរ | | | |
|---|---|---|---|
| ផ្នែក | តម្លៃទិញ | ចំនួនខែ | ចំណាយ/ខែ |
| ការជួលប្រចាំខែសម្រាប់បុគ្គលិកផ្សារ | - | - | $4.00 |
| ការជួលទូតាំងប្រចាំខែក្នុងហាងកាហ្វេ | - | - | $1.00 |
| តុសម្រាប់តូបក្នុងផ្សារ | $10 | 24 | $0.4 |
| ប័ណ្ណព័ត៌មានអាជីវកម្ម | $5 | 12 | $0.2 |
| សញ្ញាសម្រាប់តូបក្នុងផ្សារ | $10 | 24 | $0.4 |
| សញ្ញាសម្រាប់ហាងកាហ្វេ | $2 | 24 | $0.8 |
| សញ្ញាសម្រាប់ទូក្នុងចំណតឡានក្រុង | $2 | 24 | $0.8 |
| ធ្វើដំណើរទៅអ្នកផលិត (ម្តង/ខែ) | - | - | $8.00 |
| ចំណាយថេរ/ខែ | $15.6 | | |

| តារាង ៣.២.៨ ៖ ចំណាយថេរ | | | |
|---|---|---|---|
| ផ្នែក | តម្លៃទិញ | ចំនួនខែ | ចំណាយ/ខែ |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| ចំណាយថេរ/ខែ | | | |

**គន្លឹះ**

- នៅពេលអ្នកចាប់ផ្តើមអាជីវកម្មជាលើកដំបូង ឬពង្រីកអាជីវកម្ម អ្នកត្រូវចំណាយប្រាក់លើចំណាយថេរ។ មានន័យថា អ្នកត្រូវបែងចែកភាគរយចំណាយសម្រាប់ផលិតផលនីមួយៗ ដែលអ្នកលក់ប្រកបដោយប្រសិទ្ធភាពដោយបន្ថែមវាលើតម្លៃលក់។
- ប្រសិនបើអ្នកបន្ថែមចំណាយរបស់អ្នក (ថេរ និងអថេរ) លើតម្លៃទិញ អ្នកនឹងបានដឹងពីគោលបំណងរបស់អ្នកក្នុងការលក់ផលិតផល ដើម្បីឲ្យអ្នករាប់បញ្ចូលចំណាយទាំងអស់។
- ចំណាយថេរមួយចំនួនត្រូវបានបែងចែករៀងរាល់ខែ ឬសប្តាហ៍ ដូចជា ការជួល ឬការធ្វើដំណើរ ប៉ុន្តែអ្នកផ្សេងទៀតបែងចែកលើសពី ១ ខែ ដើម្បីឲ្យអ្នកអាចគណនាចំណាយដោយផ្អែកលើអាយុកាលរបស់វត្ថុ (ឧ. តុអាចប្រើប្រាស់បាន ២-៣ ឆ្នាំ)។

**ចំណាយសរុប**

| តារាង ៣.២.៩ ៖ គំរូចំណាយសរុប/ខែ | |
|---|---|
| ប្រភេទចំណាយ | ចំណាយសរុប/ខែ |
| វត្ថុធាតុដើម (អថេរ) | $2.26 |
| ចំណាយលើកម្លាំងពលកម្ម (អថេរ) | $121.50 |
| ចំណាយទូទៅ (ថេរ) | $15.6 |
| ចំណាយសរុប/ខែ | $139.36 |
| ថ្លៃ x ការលក់ - ចំណាយ = ប្រាក់ចំណេញ | |

| | | | | | |
|---|---|---|---|---|---|
| ជំហានទី ១ | ថ្លៃ | X | ការលក់ | = | ការលក់ប្រចាំខែ |
| | $1.50 | | 104 | | $156.00 |
| ជំហានទី ២ | ការលក់ប្រចាំខែ | – | ចំណាយ | = | ប្រាក់ចំណេញ |
| | $156.00 | | $139.36 | | $17.00 |

## សម្គាល់

យើងគ្រាន់តែបានប្រើប្រាស់ការលក់របស់អ្នកនៅផ្សាររាត្រីថ្ងៃសៅរ៍ប៉ុណ្ណោះ។ អ្នកត្រូវធ្វើការគណនាដូចគ្នានេះសម្រាប់ចំណុចលក់ផ្សេងទៀត (ឧ. ទូក្នុងចំណតឡានក្រុង និងទូតាំងក្នុងហាងកាហ្វេ)។

| តារាង ៣.២.១០ ៖ ចំណាយសរុប/ខែ | |
|---|---|
| ប្រភេទចំណាយ | ចំណាយសរុប/ខែ |
| វត្ថុធាតុដើម (អថេរ) | |
| ចំណាយលើកម្លាំងពលកម្ម (អថេរ) | |
| ចំណាយទូទៅ (ថេរ) | |
| ចំណាយសរុប/ខែ | |
| ថ្លៃ x ការលក់ - ចំណាយ = ប្រាក់ចំណេញ | |

| | | | | | |
|---|---|---|---|---|---|
| ជំហានទី ១ | ថ្លៃ | X | ការលក់ | = | ការលក់ប្រចាំខែ |
| ជំហានទី ២ | ការលក់ប្រចាំខែ | – | ចំណាយ | = | ប្រាក់ចំណេញ |

### ៣.៣. ប្រព័ន្ធតាមដាន និងកត់ត្រា

ក្នុងផ្នែកនេះនៃឯកសារជំនួយស្មារតី យើងនឹងផ្តោតលើគំរូឯកសារហិរញ្ញវត្ថុមួយចំនួនដែលយើងអាចប្រើប្រាស់ជាប្រព័ន្ធហិរញ្ញវត្ថុសម្រាប់អាជីវកម្ម ដែលរួមមាន ៖

- ប័ណ្ណស្តុកផលិតផល
- ប្រព័ន្ធកត់ត្រាចូលបញ្ជី
    - បញ្ជីសាច់ប្រាក់
    - វិក្កយបត្រលក់
    - វិក្កយបត្រទិញ
    - បញ្ជីចំណាយ
    - បញ្ជីសាច់ប្រាក់បន្ទាប់បន្សំ

ហេតុអ្វីបានជាប្រព័ន្ធហិរញ្ញវត្ថុមានសារៈសំខាន់?

- ធានាថា អ្នកមិនភ្លេចសាច់ប្រាក់ដែលគេជំពាក់ ឬប្រាក់ដែលអ្នកជំពាក់អ្នកផ្គត់ផ្គង់ ឬអ្នកផលិត
- ផ្តល់ព័ត៌មាន និងភស្តុតាងនៃបរាជ័យ ឬជោគជ័យក្នុងអាជីវកម្ម
- ជួយអ្នកគ្រប់គ្រងកាន់តែមានប្រសិទ្ធភាព មិនខ្ជះខ្ជាយពេលវេលា ឬប្រាក់ និងមានប្រសិទ្ធភាព។

- ដឹងពីស្តុកដែលអ្នកមាន និងពេលដែលត្រូវកម្មង់ស្តុកថ្មី ដើម្បីកុំឲ្យអ្នកអស់ស្តុក ហើយអ្នកផ្តល់ពេលវេលាដល់អ្នកផលិតក្នុងការបង្កើតស្តុកថ្មី ដូចជា ការផ្តល់ការជូនដំណឹងមួយខែមុនពីផលិតផលត្រូវការ។
- បង្ហាញពីនិន្នាការពាណិជ្ជកម្ម។ ឧ. សប្តាហ៍ ឬខែដែលបានប្រាក់ចំណេញច្រើនបំផុត (នៅពេលលក់បានច្រើនបំផុត ឬជោគជ័យនៃយុទ្ធនាការធ្វើទីផ្សារ)។ ព័ត៌មានទាំងនេះជួយអ្នកក្នុងការផ្តោតលើការលក់ និងទទួលបានប្រសិទ្ធភាពបំផុតក្នុងអាជីវកម្ម។
- មានសារៈសំខាន់ ប្រសិនបើអ្នកចង់ខ្ចីប្រាក់ ឬការគាំទ្រផ្នែកហិរញ្ញវត្ថុ។

**គន្លឹះ**

**ការទទួលបានព័ត៌មានថ្មីៗពីឯកសារ និងប្រព័ន្ធហិរញ្ញវត្ថុមិនមែនជារឿងងាយស្រួលឡើយ។**

- បង្កើតទម្លាប់ល្អដោយរៀបចំឯកសារអាជីវកម្ម និងបញ្ចូលព័ត៌មានរាល់ថ្ងៃ ឬយ៉ាងហោចណាស់រៀងរាល់សប្តាហ៍
- ចាត់ទុកឯកសារទាំងនោះជាផ្នែកមួយនៃអាជីវកម្ម ដូចជា ការដំឡើងតូបក្នុងផ្សារ និងការបែងចែកពេលវេលាសម្រាប់កិច្ចការនេះ។
- នៅពេលបំពេញការងារនេះកាន់តែច្រើន អ្នកនឹងកាន់តែមានប្រសិទ្ធភាព។
- ស្រាវជ្រាវតាមអ៊ីនធើរណិត ដើម្បីដឹងពីការបង្ហាញជាក់ស្តែងមួយចំនួនអំពីការកត់ត្រាចូលបញ្ជី និងការរៀបចំគណនេយ្យ។

| តារាង ៣.២.១១ ៖ ប្រព័ន្ធតាមដាន និងកត់ត្រា |
| --- |
| វិធានល្អបំផុតនៃការគ្រប់គ្រងហិរញ្ញវត្ថុ ៖<br>• រក្សាប្រាក់អាជីវកម្មឲ្យនៅដាច់ពីប្រាក់ផ្ទាល់ខ្លួន<br>• ប្រសិនបើអ្នកមានប្រាក់កម្ចី ត្រូវប្រើប្រាស់សម្រាប់តែអាជីវកម្មប៉ុណ្ណោះ មិនមែនផ្ទាល់ខ្លួននោះទេ។<br>• កត់ត្រាប្រតិបត្តិការហិរញ្ញវត្ថុរបស់អ្នក (ចេញ-ចូល) រៀងរាល់ថ្ងៃ។<br>• គណនាប្រាក់ចំណេញ ឬការខាតបង់រៀងរាល់ខែ។<br>• រៀបចំផែនការទិញ និងចំណាយរបស់អ្នក ដោយបែងចែកប្រាក់មួយចំនួនសម្រាប់ការទូទាត់វិក្កយបត្រធំៗប្រចាំខែ (ឧ. ការជួល)។<br>• ត្រូវដឹងពីស្តុក និងសាច់ប្រាក់ ដើម្បីកុំឲ្យបាត់បង់ ខូចខាត ឬចោរលួច។<br>• គ្រប់គ្រងការលក់តាមឥណទានរបស់អ្នក (ឧ. កត់ត្រាផលិតផល និងស្តុកដែលផ្តល់ដល់អ្នកផ្សេងដោយមិនមានការទូទាត់ ដូចជា ការលក់ក្នុងហាងកាហ្វេ ឬចំណតឡានក្រុង)។ |
| ការវិនិយោគក្នុងអាជីវកម្ម ៖<br>• ប្រាក់កម្ចីអាចមានសារៈប្រយោជន៍នៅពេលចាប់ផ្តើមអាជីវកម្ម និងពង្រីកអាជីវកម្ម។ ត្រូវខ្ចីប្រាក់សម្រាប់តែករណីចាំបាច់ប៉ុណ្ណោះ។<br>• ប្រាក់កម្ចីមិនគួរត្រូវបានប្រើប្រាស់ដើម្បីបំពេញចន្លោះខ្វះខាត នៅពេលអាជីវកម្មបរាជ័យឡើយ ព្រោះការទូទាត់ការប្រាក់នឹងបង្កើនការខ្វះខាតនោះ។<br>• ប្រើប្រាស់ប្រាក់បៀវត្សរ៍របស់អ្នកមួយចំនួនដើម្បីវិនិយោគឡើងវិញក្នុងអាជីវកម្ម និងពង្រីក។ |
| ប្រើប្រាស់ប្រព័ន្ធរៀបចំគណនេយ្យជាប្រអប់ដើម្បីគ្រប់គ្រងសាច់ប្រាក់ ៖<br>• ជួយរៀបចំផែនការ តាមដាន និងគ្រប់គ្រងសាច់ប្រាក់ (អាជីវកម្ម និងផ្ទាល់ខ្លួន)<br>• ប្រើប្រាស់ប្រព័ន្ធជាប្រអប់ ៣<br>• សាច់ប្រាក់ចូល<br>• ចំណាយក្នុងអាជីវកម្ម<br>• ចំណាយផ្ទាល់ខ្លួន<br>• សូមមើលឯកសារគំរូ។ |
| ការតាមដាន និងគ្រប់គ្រងការខាតបង់ - បញ្ហាទូទៅ ៖<br>• ផលិតផលមានគុណភាពមិនល្អ |

- ផលិតផលខូចខាតជាកំហុសរបស់អ្នកផលិត ឬជាកំហុសរបស់អ្នក ពាក់ព័ន្ធនឹងការរក្សាទុកផលិតផលមិនបានល្អ
- ប្រាក់កម្ចីមិនត្រូវបានប្រើប្រាស់សម្រាប់តែអាជីវកម្មនោះទេ (ប្រើប្រាស់ផ្ទាល់ខ្លួន)
- ផលិតផលលក់មិនដាច់ ឬមានតម្រូវការទាប (ការទិញមិនត្រឹមត្រូវ មិនមានការពិនិត្យតម្រូវការ)
- ផលិតផល និង/ឬ ប្រាក់ត្រូវបានចោរលួច។ រក្សាកំណត់ត្រាជាលាយលក្ខណ៍អក្សរ ចាក់សោរ និង/ឬ ទុកប្រាក់ជាសម្ងាត់
- ប្រសិនបើអ្នកជំពាក់ប្រាក់ សូមព្រមព្រៀងលើកាលបរិច្ឆេទទូទាត់សង បន្ទាប់មកតាមដានជាប្រចាំ។

ការតាមដាន និងគ្រប់គ្រងឥណទាន (ការលក់) ៖

- ទាំងនេះជាចំណុចសំខាន់ ព្រោះនៅពេលអ្នកលក់ផលិតផលដោយមិនទទួលបានការទូទាត់មានន័យថា អ្នកខាតបង់។
- ការលក់តាមឥណទានបង្កហានិភ័យ។ អ្នកគួរបញ្ចៀសការលក់ប្រភេទនេះ។
- ប្រសិនបើអ្នកត្រូវផ្តល់ឥណទាន សូមវាយតម្លៃទៅតាមបុគ្គល និងកាលៈទេសៈរបស់ពួកគេ។
- កត់ត្រាឥណទាន។ សរសេរពីបុគ្គល ទឹកប្រាក់ និងកាលបរិច្ឆេទសង។
- ស្នើឲ្យបុគ្គលនោះតម្កល់វត្ថុមានតម្លៃប្រហាក់ប្រហែលគ្នា (ឧ. នាឡិការដៃ ឬឯកសារម៉ូតូ)។
- ពិចារណាពីការកំណត់ថ្លៃខ្ពស់សម្រាប់ផលិតផលឥណទាន និងរក្សាទុកសាច់ប្រាក់បន្ថែមដោយឡែក ក្នុងករណីអ្នកទិញមិនសងប្រាក់ជំពាក់។

ការគ្រប់គ្រងស្តុកផលិតផល ៖

- កត់ត្រារាល់ការទិញស្តុកដើម្បីបញ្ចូលកាលបរិច្ឆេទ លេខ ID ផលិតផល ចំនួនផលិតផលទិញ
- កត់ត្រារាល់ការលក់ស្តុកទាំងអស់ដើម្បីបញ្ចូលកាលបរិច្ឆេទ អតិថិជន ប្រាក់ទទួលបាន/ឥណទានដែលផ្តល់ឲ្យ និងចំនួនផលិតផល
- រក្សាឲ្យស្តុកមានតុល្យភាព ដើម្បីឲ្យអ្នកបានដឹងពីអ្វីដែលអ្នកបានទិញគ្រប់ពេល អ្វីដែលអ្នកបានលក់ និងអ្វីដែលអ្នកមានក្នុងស្តុក
- ត្រូវចាំថា ស្តុកដែលមាន (ទិញ ប៉ុន្តែមិនទាន់បានលក់ចេញ) គឺជាទ្រព្យសកម្មអាជីវកម្ម ហើយទ្រព្យសកម្មជាផ្នែកនៃកម្មសិទ្ធិក្នុងអាជីវកម្ម។ ដូច្នេះ សូមចាត់ទុកវាដូចសាច់ប្រាក់របស់អ្នក។

| តារាង ៣.២.១២ ៖ ប្រព័ន្ធកក់ទុក | |
|---|---|
| ប្រព័ន្ធកត់ត្រាចូលបញ្ជីសំខាន់ៗ | និយមន័យ |
| បញ្ជីសាច់ប្រាក់ | ជាវិធីកត់ត្រាចូលបញ្ជីដ៏សំខាន់ដើម្បីកត់ត្រាប្រាក់ចំណូល និងចំណាយ ដែលត្រូវមានបញ្ជីសាច់ប្រាក់ និងម៉ាស៊ីនគិតលេខ។ មិនមានការកត់ត្រាពីទ្រព្យសកម្ម បំណុល និងទ្រព្យម្ចាស់ដូចក្នុងសៀវភៅបញ្ជីធំឡើយ។ ដូច្នេះ វាមិនអាចប្រើប្រាស់ដើម្បីបង្កើតជាតារាងតុល្យការហិរញ្ញវត្ថុបានឡើយ។ នេះមិនមែនជាបញ្ហាសម្រាប់អាជីវកម្មខ្នាតតូចឡើយ។ |
| វិក្កយបត្រលក់ | ជាវិធីកត់ត្រាចូលបញ្ជីដ៏សំខាន់ដើម្បីកត់ត្រាអ្នកទិញផលិតផល និងអ្នកជំពាក់ប្រាក់។ វិក្កយបត្រលក់នឹងត្រូវផ្តល់ឲ្យអ្នកដែលទិញដុំពីអ្នក។ ឧ. មិនមែនជាអ្នកទិញដោយបង់ប្រាក់តាមទីផ្សារឡើយ។ វាអាចប្រើប្រាស់សម្រាប់ផ្តល់ការបញ្ចុះតម្លៃសម្រាប់ការទូទាត់លឿន។ អតិថិជនផ្តល់វិក្កយបត្រទូទាត់ ដើម្បីឲ្យអ្នកដឹងពីអ្នកបង់ប្រាក់។ ប្រការល្អបំផុតត្រូវមានឯកសារពីរ ចេញ និងទូទាត់។ សរសេរវិក្កយបត្រ និងរក្សាច្បាប់ចម្លងក្នុងឯកសារចេញ។ នៅពេលអ្នកទទួលបានការទូទាត់ សូមសរសេរពាក្យ "បង់ប្រាក់" លើវិក្កយបត្រ រួចដាក់វាក្នុងឯកសារបង់ប្រាក់។ |
| ការបញ្ជាទិញ | ជាវិធីកត់ត្រាចូលបញ្ជីដ៏សំខាន់ដើម្បីកត់ត្រាអ្វីដែលអ្នកបានទិញ (ឧ. ស្តុកគ្រឿងបរិក្ខារ) និងប្រាក់ដែលអ្នកជំពាក់ (ឧ. ចំណាយក្នុងអាជីវកម្ម)។ អាជីវករ ឬអ្នកផ្គត់ផ្គង់ (សិប្បករ) ដែលអ្នកជំពាក់ប្រាក់ ហៅថា ឥណទាយក។ អ្នកអាចរក្សាចំណុចទាំងនេះក្នុងឯកសារពីរ ៖ ចេញ និងបង់ប្រាក់។ ម្ចាស់អាជីវកម្មគួរគ្រប់គ្រងវិក្កយបត្រទិញទាំងអស់ដោយធានាថា ថ្លៃត្រូវបានព្រមព្រៀងជាមួយអ្នកផ្គត់ផ្គង់ជាមុន និងត្រូវបានពិនិត្យផ្ទៀបនឹងវិក្កយបត្ររបស់អ្នកផ្គត់ផ្គង់នៅពេលទំនិញមកដល់ ពោលគឺវាគួរតែត្រូវគ្នានឹងការរៀបរាប់ បរិមាណ និងតម្លៃ។ ប្រសិនបើមានភាពខុសគ្នា អ្នកគួរផ្តល់ដំណឹងដល់អ្នកផ្គត់ផ្គង់ភ្លាម។ អ្នកអាចប្រើប្រាស់គំរូឯកសារគណនីសម្រាប់បង់ ដើម្បីសង្ខេបពីការបញ្ជាទិញដែលបង្ហាញពីទឹកប្រាក់ជំពាក់ និងកាលបរិច្ឆេទទូទាត់។ |
| បញ្ជីចំណាយ និងបង្កាន់ដៃ | ជាវិធីកត់ត្រាចូលបញ្ជីដ៏សំខាន់ដើម្បីកត់ត្រាពីការបង់ប្រាក់ក្នុងអាជីវកម្មពាក់ព័ន្ធនឹងចំណាយដែលត្រូវទូទាត់ជំនួសមុខឲ្យអាជីវកម្ម។ ឧ. ប្រសិនបើអ្នកស្នើឲ្យមិត្តភក្តិប្រមូលការកម្មង់របស់អ្នកពីអ្នកផ្គត់ផ្គង់ក្នុងពេលដែលគាត់កំពុងចុះទៅតំបន់ដែលអ្នកនឹងទូទាត់ចំណាយដើម្បីគ្របដណ្តប់លើចំណាយមួយចំនួនរបស់គាត់។ បង្កាន់ដៃ ដូចជាសំបុត្រឡានក្រុងគួរមានចំណាយ |

| | |
|---|---|
| | ទាំងនេះ។ អាជីវកម្មអាចចេញបង្កាន់ដៃសម្រាប់ទំនិញលក់ចេញដល់អតិថិជនបាន។ |
| សាច់ប្រាក់បន្ទាប់បន្សំ | ជាវិធីកត់ត្រាចូលបញ្ជីដ៏សំខាន់ដើម្បីកត់ត្រាការទូទាត់សាច់ប្រាក់បន្ទាប់បន្សំសម្រាប់ផ្នែក/មុខក្នុងអាជីវកម្មប្រចាំថ្ងៃ ដូចជា តែ និងកាតទូរស័ព្ទ។ ប្រអប់សាច់ប្រាក់បន្ទាប់បន្សំអាចប្រើប្រាស់សម្រាប់រក្សាទុកសាច់ប្រាក់ទទួលបានពីអតិថិជន។ អ្នកចាប់ផ្ដើមពីលុយរាយក្នុងសាច់ប្រាក់បន្ទាប់បន្សំ (ឧ. ៥០ ដុល្លា)។ រាល់ប្រតិបត្តិការទាំងអស់ (ចេញ និងចូល) ត្រូវបានកត់ត្រាក្នុងសក្ខីបត្របេឡាដែលត្រូវបានបញ្ចូលទៅក្នុងសៀវភៅបញ្ជីសាច់ប្រាក់បន្ទាប់បន្សំ។ នៅចុងខែ អ្នក "បន្ថែមចូល" ប្រអប់សាច់ប្រាក់បន្ទាប់បន្សំឲ្យនៅត្រឹមទឹកប្រាក់រាយដំបូង (៥០ ដុល្លា)។ |
| ប័ណ្ណគ្រប់គ្រងស្តុក | ជាវិធីកត់ត្រាចូលបញ្ជីដ៏សំខាន់ដើម្បីកត់ត្រាព័ត៌មានលម្អិតពីស្តុករបស់អ្នក (ឧ. វត្ថុដែលបានទិញ)។ ត្រូវចាំថា ស្តុកគឺជាប្រាក់។ ប័ណ្ណស្តុកនឹងកត់ត្រាបរិមាណស្តុកដែលបានទិញក្នុងអំឡុងពេលមួយ ដើម្បីឲ្យអ្នកមានព័ត៌មានពីផលិតផលលក់ដាច់បំផុត។ វានឹងរំលឹកអ្នកពីពេលដែលត្រូវកម្មង់ដើម្បីកុំឲ្យដាច់ស្តុក ហើយវាអាចប្រើប្រាស់ដើម្បីបង្ហាញពីការលួច ឬការខូចខាត។ |

## បញ្ជីសាច់ប្រាក់

តារាង ៣.២.១៣ ៖ គំរូការកត់ត្រាចូលបញ្ជី ៖ បញ្ជីសាច់ប្រាក់

ប្រព័ន្ធ ៣ ប្រអប់ (ប្រាក់ចេញ និងចូលក្នុងអាជីវកម្ម និងសាច់ប្រាក់ផ្ទាល់ខ្លួន)

| ខែ: មករា<br>ឆ្នាំ: 2014 | ការរៀបរាប់ | ប្រាក់ចូលក្នុងអាជីវកម្ម | ប្រាក់ចេញពីអាជីវកម្ម | ចំណាយផ្ទាល់ខ្លួន | សមតុល្យ |
|---|---|---|---|---|---|
| 01.01 | ប្រាក់កម្ចីដើម្បីបង្កើតអាជីវកម្ម | 1000.00 | | | |
| 01.01 | ការធ្វើដំណើរទៅអ្នកផលិតក្នុងភូមិ | | 8.00 | | |

| | | | | | |
|---|---|---|---|---|---|
| 01.01 | ទិញផលិតផល (80 x $1) | | 80.00 | | |
| 03.01 | ការជួលតូបនៅខែមករា | | 4.00 | | |
| 03.01 | ការជួលទូតាំងនៅខែមករា | | 1.00 | | |
| 03.01 | តុសម្រាប់លក់ផលិតផល | | 10.00* | | |
| 03.01 | ប័ណ្ណផ្សព្វផ្សាយពាណិជ្ជកម្ម | | 5.00* | | |
| 03.01 | សញ្ញា ($10 និង 2 x $2) | | 14.00* | | |
| 04.01 | ការលក់ផលិតផល<br>សប្តាហ៍ទី 1 - 15 x $1.50 | 22.50 | | | |
| 11.01 | ការលក់ផលិតផល<br>សប្តាហ៍ទី 2 - 22 x $1.50 | 33.00 | | | |
| 18.01 | ការលក់ផលិតផល<br>សប្តាហ៍ទី 3 - 23 x $1.50 | 34.50 | | | |
| 25.01 | ការលក់ផលិតផល<br>សប្តាហ៍ទី 4 - 20 x £1.50 | 30.00 | | | |
| 26.01 | ប្រាក់ឈ្នួលរបស់ខ្ញុំ (5 ម៉ោង x 6 ថ្ងៃ x 4 សប្តាហ៍ ក្នុងតម្លៃ $1/ម៉ោង) | | | $120.00 | |
| សរុប | | $1120.00 | $122.00 | $120.00 | $878.00 |

## គំរូ ៖ ការវិភាគហិរញ្ញវត្ថុ

- ប្រាក់ចេញគឺ ១២២ ដុល្លា (ចំណាយក្នុងអាជីវកម្ម) + ១២០ ដុល្លា (ប្រាក់ឈ្នួល)
- ផលិតផលចំនួន ៨០ ត្រូវបានលក់ក្នុងខែនេះ។ អ្នកបង់ ១ ដុល្លា/ផលិតផល និងលក់ក្នុងតម្លៃ ១,៥០ ដុល្លា ដែលធ្វើឲ្យអ្នកចំណេញបាន ៤០ ដុល្លា។ បន្ទាប់មក អ្នកត្រូវដកចំណាយប្រចាំខែ (១៣៩,៣៦ ដុល្លា ដែលបានប៉ាន់ស្មានក្នុងសកម្មភាពមុន ៖ នេះជាតួលេខដែលរួមបញ្ចូលប្រាក់ឈ្នួល ១២០ ដុល្លា)។
- អ្នកមានទុនវិនិយោគ (១.០០០ ដុល្លា) ដែលអ្នកនឹងអាចទូទាត់សង នៅពេលអាជីវកម្មដំណើរការល្អ ហើយអ្នកទទួលបានប្រាក់ឈ្នួល ១២០ ដុល្លា។ ប្រសិនបើអ្នកមិនគិតប្រាក់ឈ្នួលសម្រាប់រយៈពេល ៣ ខែដំបូង ខណៈពេលកំពុងបង្កើតអតិថិជន តួលេខនេះមិនចោទជាបញ្ហាឡើយ។
- ក្រៅពីនេះ អ្នកបានបង់ប្រាក់ ២៩ ដុល្លាសម្រាប់ចំណាយថេរ (តុ សញ្ញា ប័ណ្ណព័ត៌មាន) ដែលអាចប្រើប្រាស់ជាច្រើនខែ ប៉ុន្តែវាមាននៅខែដែលអ្នកបានទិញ។
- នៅពេលអ្នកកត់ត្រាចូលបញ្ជីសម្រាប់ខែបន្ទាប់ (កុម្ភៈ) សូមគណនា ៨៧៨ ដុល្លា និងបញ្ចូលក្នុងផ្នែកលើនៃកូឡោនទី ១ (ឧ. ទីតាំងតួលេខ ១.០០០ ដុល្លាក្នុងតារាងខាងលើ)។ នេះជាសមតុល្យចាប់ផ្ដើមប្រចាំខែថ្មីរបស់អ្នក។

តារាង ៣.២.១៤ ៖ ការកត់ត្រាចូលបញ្ជី - បញ្ជីសាច់ប្រាក់

| ខែ<br>ឆ្នាំ | ការរៀបរាប់ | ប្រាក់ចូលក្នុងអាជីវកម្ម | ប្រាក់ចេញពីអាជីវកម្ម | ចំណាយផ្ទាល់ខ្លួន | សមតុល្យ |
|---|---|---|---|---|---|
| 01st | | | | | |
| 2nd | | | | | |
| 3rd | | | | | |
| 4th | | | | | |
| 5th | | | | | |
| 6th | | | | | |
| 7th | | | | | |

| | | | | | |
|---|---|---|---|---|---|
| 8th | | | | | |
| 9th | | | | | |
| 10th | | | | | |
| 11th | | | | | |
| 12th | | | | | |
| 13th | | | | | |
| 14th | | | | | |
| 15th | | | | | |
| 16th | | | | | |
| 17th | | | | | |
| 18th | | | | | |
| 19th | | | | | |
| 20th | | | | | |
| 21st | | | | | |
| 22nd | | | | | |
| 23rd | | | | | |
| 24th | | | | | |
| 25th | | | | | |
| 26th | | | | | |
| 27th | | | | | |
| 28th | | | | | |
| 29th | | | | | |
| 30th | | | | | |
| 31st | | | | | |
| សរុប | | | | | |

## វិក្កយបត្រលក់

តារាង ៣.២.១៥ ៖ វិក្កយបត្រលក់

| វិក្កយបត្រលក់ | |
|---|---|
| កាលបរិច្ឆេទ ៖ | លេខវិក្កយបត្រ ៖ |
| ផ្ញើជូន ៖ | ពី ៖ |

| បរិមាណ | ការរៀបរាប់ | ថ្លៃ/ឯកតា | ចំណាយ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

| | |
|---|---|
| មតិយោបល់ ៖ | សរុបរង ៖ |
| | បញ្ចុះតម្លៃ ៖ |
| | ពន្ធ ៖ |

| | |
|---|---|
| | |
| | ប្រាក់ជំពាក់សរុប ៖ |
| កាលបរិច្ឆេទបង់ប្រាក់ ៖ | |
| គណនីធនាគារ ៖ | |
| ការប្រាក់ __% ក្នុងមួយឆ្នាំនឹងត្រូវបានបូកបន្ថែមលើការទូទាត់យឺត។ | |
| *កាត់ចេញ* | |
| ការផ្ញើប្រាក់ | ឈ្មោះអតិថិជន ៖ |
| | លេខវិក្កយបត្រ ៖ |
| | ប្រាក់ដែលបានបង់ ៖ |

## ការបញ្ជាទិញ

| តារាង ៣.២.១៦ ៖ ការកត់ត្រាចូលបញ្ជី ៖ ការបញ្ជាទិញ |
|---|
| (ស្លាកសញ្ញារបស់អ្នក) ការកម្មង់លេខ ៖.................................................. |
| កាលបរិច្ឆេទកម្មង់ ៖ ....................................................... |
| កាលបរិច្ឆេទបញ្ជូនដល់ ៖ ...................................... |

អ្នកផ្គត់ផ្គង់ ៖

..........................................................

..........................................................

អ្នកទិញ (អ្នក)

..........................................................

..........................................................

..........................................................

| លេខផលិតផល | ការរៀបរាប់ពីផលិតផល | បរិមាណ | ថ្លៃ/ឯកតា | សរុប |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

| | | | | |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| មតិយោបល់ ៖ | | សរុបរង ៖ | | |
| | | ពន្ធ (អត្រា % ប្រសិនបើ អាចអនុវត្តបាន) | | |
| | | ប្រៃសណីយ៍/ដឹកជញ្ជូន | | |
| | | ជំពាក់សរុប ៖ | | |

## ទម្រង់ចំណាយ និងបង្កាន់ដៃ

តារាង ៣.២.១៧ ៖ ទម្រង់ចំណាយ និងបង្កាន់ដៃ

កាលបរិច្ឆេទ ....................................

| ព័ត៌មានលម្អិត ៖ | បង្កាន់ដៃ បាទ/ចាស/ទេ | បរិមាណ |
|---|---|---|
| | | |

| | | |
|---|---|---|
| | | |
| | | |
| | | |
| សរុប | | |

បង់ប្រាក់ដោយ (ផ្តិតមេដៃ និងចុះហត្ថលេខា)

……………………………………………………………………………………………………

ទទួលប្រាក់ដោយ (ផ្តិតមេដៃ និងចុះហត្ថលេខា)

……………………………………………………………………………………………

## សាច់ប្រាក់បន្ទាប់បន្សំ

តារាង ៣.២.១៨ ៖ សៀវភៅបញ្ជីសាច់ប្រាក់បន្ទាប់បន្សំ

ខែ ៖

| កាលបរិច្ឆេទ | ព័ត៌មានលម្អិត | ប្រាក់ចូល | ប្រាក់ចេញ | សមតុល្យ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

| | | | | |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| សាច់ប្រាក់សរុបនៅសល់ ៖ | | | | |

| | | | | | |
|---|---|---|---|---|---|
| ប្រាក់រាយ | | សាច់ប្រាក់សរុបនៅសល់តិច | | = ប្រាក់បន្ថែមចូល | |

តារាង ៣.២.១៩ ៖ សក្ខីបត្របេឡាបន្ទាប់បន្សំ

| | | | |
|---|---|---|---|
| សក្ខីបត្របេឡាបន្ទាប់បន្សំ | | | |
| កាលបរិច្ឆេទ | | ប្រាក់ចេញ | |
| ព័ត៌មានលម្អិត | | ប្រាក់ចូល | |
| | | សរុប | |
| លេខសក្ខីបត្រ | | | |
| | | | |
| សក្ខីបត្របេឡាបន្ទាប់បន្សំ | | | |
| កាលបរិច្ឆេទ | | ប្រាក់ចេញ | |
| ព័ត៌មានលម្អិត | | ប្រាក់ចូល | |
| | | សរុប | |
| លេខសក្ខីបត្រ | | | |
| សក្ខីបត្របេឡាបន្ទាប់បន្សំ | | | |
| កាលបរិច្ឆេទ | | ប្រាក់ចេញ | |
| ព័ត៌មានលម្អិត | | ប្រាក់ចូល | |
| | | សរុប | |
| លេខសក្ខីបត្រ | | | |

## ស្តុកផលិតផល

តារាង ៣.២.២០ ៖ ប័ណ្ណស្តុកផលិតផល

ឈ្មោះផលិតផល ៖ កាបូបលុយបុរស

កូដផលិតផល ៖ MW1

អាសយដ្ឋានទំនាក់ទំនងរបស់អ្នកផ្គត់ផ្គង់/អ្នកផលិត ៖

| ការរៀបរាប់ ៖ | តម្លៃ និងតម្លៃលក់ | មតិយោបល់ ៖ |
|---|---|---|
| | ទិញ<br>លក់ | |

| កាលបរិច្ឆេទ | ចូល (B/F) | ចេញ | សមតុល្យ | មតិយោបល់ ៖ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |

| | | | | |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| សរុប | | | | |

**គន្លឹះ**

- អ្នកអាចប្រើប្រាស់សន្លឹកមួយសម្រាប់ផលិតផលមួយ និងដាក់កូដផលិតផល ប្រសិនបើអ្នកមានប្រភេទផលិតផលកាបូបបុរសលើសពីមួយ។
- ដាក់កូដធម្មតាដែលអ្នកអាចចាំបាន។ ប្រសិនបើផលិតផលមានទំហំតូច/មធ្យម/ធំ អ្នកអាចសរសេរថា MWL។
- ប្រសិនបើអ្នកផ្តល់ផលិតផលជាឥណទាន ឬការលក់ ដូចដែលអ្នកផ្តល់ដល់អ្នកលក់ផលិតផលរបស់អ្នកក្នុងហាងរបស់ពួកគេ (ឧ.ហាងកាហ្វេ ឬចំណតឡានក្រុង) អ្នកអាចប្រើប្រាស់ប័ណ្ណនេះ និងដាក់ព័ត៌មានលម្អិត (ដូចខាងលើ**)។ ពួកគេទូទាត់ប្រាក់ឲ្យអ្នក នៅពេលពួកគេបានលក់ផលិតផលដាច់ ប៉ុន្តែអ្នកត្រូវកត់ត្រាស្តុក។

**របាយការណ៍ប្រាក់ចំណេញ និងការខាតបង់**

| តារាង ៣.២.២១ ៖ របាយការណ៍ប្រាក់ចំណេញ និងការខាតបង់ | | | |
|---|---|---|---|
| ប្រាក់ចំណូល | | | |
| ការរៀបរាប់ | បរិមាណ | | |
| | | | |
| | | | |
| | | | |
| | | | |
| | ប្រាក់ចំណូលសរុប | | |
| | | | |
| ថ្លៃដើមទំនិញលក់ចេញ | | | |
| ការរៀបរាប់ (ឧ. ស្តុក សន្និធិ វត្ថុធាតុដែលបានលក់ឲ្យអតិថិជន។ល។) | បរិមាណ | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | ចំណាយសរុបលើការលក់ | | |
| | | ប្រាក់ចំណេញដុល (ប្រាក់ចំណូលសរុបដកចំណាយលើការលក់) | |
| | | | |
| ចំណាយ | | | |
| ការរៀបរាប់ (ឧ. ការផ្សាយពាណិជ្ជកម្ម | បរិមាណ | | |

| | | | |
|---|---|---|---|
| ប្រៃសណីយ៍ ប្រេងឥន្ធនៈ។ល។) | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | ចំណាយសរុប | | |
| | | ប្រាក់ចំណេញសុទ្ធ (ប្រាក់ចំណេញដុល ដកចំណាយ) | |


LUX
PAGODA
PAGODA
PAGODA
Palmolive
Naturals
PANTENE